# រាជរដ្ឋាភិបាលកម្ពុជា

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦ - ២០១៨

**ធ្នូ ២០១៥**

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍ ធ្លាប់រងនូវមហាវិនាសកម្មដ៏ធ្ងន់ធ្ងរដែលបង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនរាប់លាននាក់ និងបំផ្លាញសង្គមជាតិខ្ទេចខ្ទីដល់ឫសគល់ ក្នុងនោះកុមារក៏ត្រូវរងនូវការកាប់សម្លាប់ ធ្វើទារុណកម្មគ្រប់បែបយ៉ាង ដែលធ្វើឱ្យកម្ពុជាបាត់បង់ធនធានមនុស្សជាច្រើន។ ក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ ទន្ទឹមនឹងការស្តារនិងអភិវឌ្ឍន៍ប្រទេសពីបាតដៃទទេ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារកម្ពុជាត្រូវបានការពារនិងលើកតម្កើង ដោយចាត់ទុកកុមារជាអ្នកបន្តវេនរបស់ប្រទេសជាតិដូចពាក្យស្លោកថា កុមារជាទំពាំងស្នងឫស្សី។

បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបោះជំហានទៅមុខក្នុងការស្តារសង្គមនិងសេដ្ឋកិច្ចឡើងវិញ ដែលតម្រូវឱ្យកសាងធនធានមនុស្សជំនាញនិងប្រជាជនដែលមានសុខភាពល្អក្នុង២ទសវត្សរ៍ចុងក្រោយនេះ ដោយមានកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ហើយផលិតផលក្នុងស្រុកបានកើនឡើងជាង១០០០ដុល្លារក្នុងម្នាក់ បើប្រៀបធៀបកាលពីមួយទសវត្សរ៍មុនគឺទទួលបានតិចជាង២០០ដុល្លារក្នុងម្នាក់ ហើយអត្រាភាពក្រីក្រត្រូវបានកាត់បន្ថយមកត្រឹមប្រមាណ១៦%នៅឆ្នាំ២០១៣ ធ្វើឱ្យកម្ពុជាបោះជំហានចេញពីប្រទេសមានចំណូលកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ រាជរដ្ឋាភិបាលបានវិភាជធនធានបន្ថែមទៀតដល់វិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលក្នុងនោះបានផ្តោតសំខាន់លើការអភិវឌ្ឍសុខុមាលភាពកុមារផងដែរ។

ស្របតាមស្ថានភាពកុមារមានភាពរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន មានជាអាទិ៍ អនុសញ្ញាស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២ ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅឆ្នាំ២០០២ អនុសញ្ញាលេខ១៣៨ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ១៩៩៩ អនុសញ្ញាលេខ១៨២ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅឆ្នាំ២០០៥ និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេសនៅឆ្នាំ២០០៧។

ក្នុងនាមជាប្រទេសហត្ថលេខី រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងកុមារ និងផែនការអភិវឌ្ឍតាមវិស័យរយៈពេលវែងនិងមធ្យមផ្សេងៗទៀត ដើម្បីធានាការអភិវឌ្ឍ ផ្តល់ការងារសមស្រប សមភាព ប្រសិទ្ធភាព និងធានាឱ្យសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥ រួមទាំងបង្កើតយន្តការជាច្រើននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីសម្របសម្រួលដល់ការអនុវត្តលិខិតបទដ្ឋានគតិយុត្ត រួមទាំងគោលនយោបាយនិងផែនការសកម្មភាពដូចបានបញ្ជាក់ខាងលើ។

ទន្ទឹមនឹងការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការជាតិជាច្រើនទាក់ទងទៅនឹងការលើកកម្ពស់និងការការពារសិទ្ធិកុមារ កុមារកម្ពុជានៅតែជួបបញ្ហាប្រឈមមួយចំនួននៅឡើយដូចជា កុមារបោះបង់

ការសិក្សា កុមារបម្លាស់ទី អំពើហិង្សាលើកុមារ ការប្រើប្រាស់គ្រឿងញៀន កុមារកង្វះអាហារូបត្ថម្ភ។ល។ ដែលតម្រូវឱ្យក្រសួង ស្ថាប័ន អាជ្ញាធរ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ ឪពុកម្តាយ រួមគ្នាដោះស្រាយឱ្យបានទាន់ពេលវេលា និងចំគោលដៅ។

នេះគឺជាជំហានថ្មីមួយទៀត ដែលរាជរដ្ឋាភិបាលបានបង្កើតផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារដាច់ដោយឡែកដែលនឹងដាក់ឱ្យអនុវត្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ ស្របតាមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីធានាថាបញ្ហាកុមារត្រូវបានដាក់បញ្ចូលទៅគ្រប់វិស័យពាក់ព័ន្ធក្នុងការលើកកម្ពស់សិទ្ធិ សុវត្ថិភាព ស្ថានភាព និងជំនាញរបស់កុមារ។ ការវិនិយោគជាមួយកុមារ គឺជាការងារអាទិភាព ដោយសារការវិនិយោគលើកុមារនៅថ្ងៃនេះនឹងបង្កើតបានជាធនធានមនុស្សដែលមានជំនាញនិងប្រកបដោយសក្តានុពលនាពេលអនាគត ដើម្បីធានាចីរភាពកំណើនសេដ្ឋកិច្ចនិងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន។

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ មានយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដោយផ្តោតទៅលើការលើកកម្ពស់គុណភាពអប់រំនិងបណ្តុះបណ្តាលជំនាញ លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ ពង្រឹងកិច្ចការពារនិងបង្ការទប់ស្កាត់កុមារពីអំពើហិង្សា និងការងារប្រកបដោយគ្រោះថ្នាក់ ពង្រឹងកិច្ចសហការការអនុវត្តច្បាប់ ក្របខណ្ឌគតិយុត្ត និងគោលនយោបាយ ពង្រឹងយន្តការជាតិ សមត្ថភាពបំពេញមុខងារនិងដំណើរការល្អ។ ដើម្បីធានាដល់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យ ខ្ញុំស្នើឱ្យមានការតាមដានត្រួតពិនិត្យនិងការវាយតម្លៃនិងការធ្វើបច្ចុប្បន្នកម្មជាប្រចាំ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់កុមារ ហើយតាមរយៈការអនុវត្តផែនការសកម្មភាពនេះ កុមារកម្ពុជាកាន់តែទទួលបាននូវការផ្តល់សេវា និងការយកចិត្តទុកដាក់បន្ថែមទៀត មានន័យថាធ្វើសកម្មភាពផ្សេងៗគ្នាដើម្បីឈានទៅសម្រេចគោលបំណងរួមតែមួយ ដើម្បីជំរុញកម្ពុជាមានធនធានមនុស្សប្រកបដោយសក្តានុពលនាពេលអនាគត។

ខ្ញុំសូមកោតសរសើរចំពោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័ន គណៈកម្មការផែនការនិងរបាយការណ៍ជាតិស្តីពីកុមារ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការដៃគូអភិវឌ្ឍ ដែលបានរួមចំណែកដល់ការរៀបចំកសាងផែនការសកម្មភាពដ៏មានសារៈសំខាន់ ដែលជាស្នាដៃទុកជាប្រវត្តិសាស្ត្រសម្រាប់កុមារកម្ពុជា។ ខ្ញុំសូមលើកទឹកចិត្តដល់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ក្នុងការចាប់ផ្តើមអនុវត្តផែនការសកម្មភាពនេះពីពេលនេះតទៅ ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កម្ពុជានឹងអាចដោះស្រាយភាពប្រឈមទាំងអស់នេះបានដោយជោគជ័យ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខ្ញុំសូមបញ្ជាក់ថាដើម្បីទទួលបានភាពជោគជ័យនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ ដូចដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ ក្នុងន័យនេះ ខ្ញុំសូមស្នើដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធលើកគម្រោងចំណាយនានា ដើម្បីអនុវត្តសកម្មភាពអាទិភាពដែលមានចែងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ និងដាក់បញ្ចូលទៅក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នរបស់ខ្លួន។ ខ្ញុំស្នើឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ពង្រឹងតួនាទី ភារកិច្ចរបស់ខ្លួន ក្នុងការសម្របសម្រួលការងារអន្តរក្រសួង

លើវិស័យកុមារ ជាពិសេស ការងារពិនិត្យតាមដានវាយតម្លៃ និងធ្វើរបាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ។

ខ្ញុំសង្ឃឹមនិងជឿជាក់ថា ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ នឹងដាក់បញ្ចូលសកម្មភាពនានា ដែលមានចែងនៅក្នុងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ទៅក្នុងផែនការប្រតិបត្តិតាមវិស័យរបស់ខ្លួន ដើម្បីពង្រឹង ការពារ និងលើកកម្ពស់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យកាន់តែមានប្រសិទ្ធភាព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ខែ ធ្នូ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# សេចក្តីថ្លែងអំណរគុណ

ផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ គឺជាផែនការដំបូងតែមួយគត់ដែលមានលក្ខណៈសម្របសម្រួលទូលំទូលាយដោយផ្ដោតលើកុមារ ផែនការនេះមានគោលបំណងដាក់បញ្ចូលក្រសួង ស្ថាប័នរួមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តផែនការនេះ។ ផែនការនេះបានលើកឡើងនូវកម្មវិធី ឬសកម្មភាពដែលមិនជាន់គ្នាជាមួយកិច្ចប្រឹងប្រែងដែលបានធ្វើកន្លងមក ឬកម្មវិធីដែលកំពុងអនុវត្តដោយក្រសួង ស្ថាប័នដទៃទៀត ប៉ុន្តែបានកំណត់គម្លាតនៅតាមផែនការវិស័យនានា និងស្នើឡើងនូវយុទ្ធវិធីនិងមធ្យោបាយក្នុងការផ្សារភ្ជាប់គម្លាតទាំងនោះ។

ផែនការនេះ ក៏បានកំណត់ពីតម្រូវការក្នុងការចាប់ផ្ដើមសកម្មភាពរួមគ្នារបស់ក្រសួង ស្ថាប័ន ក្នុងករណីជាច្រើនដោយសារក្រសួង ស្ថាប័នតែមួយមិនអាចដោះស្រាយបញ្ហាកុមារបានពេញលេញទាំងអស់ទេ។ លើសពីនេះទៀតផែនការនេះបានស្នើឱ្យបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់កុមារ ដើម្បីតាមដានវឌ្ឍនភាពស្ដីពីកុមារ។

ខ្ញុំសូមសម្ដែងនូវការដឹងគុណចំពោះ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ដែលដឹកនាំការស្ដារនិងអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ដោយក្នុងនោះបានផ្សារភ្ជាប់ជានិច្ចកាលជាមួយនឹងបុព្វហេតុកុមារ និងផ្ដល់នូវសេចក្ដីអាណិតស្រឡាញ់និងសន្ដោសប្រណីចំពោះកុមារគ្រប់ៗរូប។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតឡើងតាំងពីឆ្នាំ១៩៩៥ គឺជាយន្តការសម្របសម្រួលនិងផ្ដល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងទៅនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ ជាអ្នកផ្ដួចផ្ដើមដឹកនាំរៀបចំផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍកុមារនេះឡើង។ ក្នុងរយៈពេល២០ឆ្នាំនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលការងារអន្តរក្រសួងលើវិស័យកុមារ ហើយបានបញ្ជ្រាបបញ្ហាកុមារទៅក្នុងច្បាប់ គោលនយោបាយ និងផែនការជាតិជាច្រើនទៀតផង។

ខ្ញុំសូមកោតសរសើរ និងថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះសមាជិក សមាជិកាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គណៈកម្មការរៀបចំផែនការនិងរបាយការណ៍ជាតិស្ដីពីកុមារ អង្គការក្លែនអន្តរជាតិកម្ពុជា អង្គការយូនីសេហ្វ អង្គការសង្គ្រោះកុមារ អង្គការ Global Alliance for Children អង្គការមិនមែនរដ្ឋាភិបាលនានា ដៃគូអភិវឌ្ឍ តំណាងកុមារនិងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមឧបត្ថម្ភគាំទ្រយ៉ាងសកម្ម ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ដំណើរការរៀបចំផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨នេះឡើង ហើយខ្ញុំសង្ឃឹមថាយើងនឹងទទួលបានកិច្ចសហប្រតិបត្តិការបន្ថែមនៅពេលអនាគត ដើម្បីឧត្តមប្រយោជន៍របស់កុមារ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
**និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**វង សូត**

# មាតិកា

**អារម្ភកថា** ............ i

**សេចក្តីថ្លែងអំណរគុណ** ............ iv

**មាតិកា** ............ v

**១- សារបាន** ............ ១

១.១- គោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះកុមារ ............ ៣

១.២- ការវិភាគស្ថានភាពកុមារ ............ ៥

១.៣- បញ្ហាអាទិភាព ............ ១១

**២- យុទ្ធសាស្ត្រ** ............ ១៣

**៣- ផែនការសកម្មភាព** ............ ១៤

៣.១- បរិយាយសង្ខេបអំពីវិសាលភាពផែនការ ............ ១៤

៣.២- តារាងអនុវត្តការងារ ............ ១៦

**៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់-លិខិតបទដ្ឋានគតិយុត្ត** ............ ៣៧

**៥- គម្រោងចំណាយ** ............ ៣៨

**៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ............ ៣៩

**៧- សេចក្តីសន្និដ្ឋាន** ............ ៤៣

**៨- សន្ទានុក្រម** ............ ៤៤

# ១- សារបាន

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានប្រជាជនប្រមាណ១៤,៧ លាននាក់នៅឆ្នាំ២០១៣ និងមានកុមារអាយុក្រោម១៨ឆ្នាំប្រមាណ៣៥% (របាយការណ៍អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣)។

ប្រវត្តិសាស្ត្រកម្ពុជា ធ្លាប់បានឆ្លងកាត់សង្គ្រាមស៊ីវិលនិងជម្លោះផ្ទៃក្នុងដ៏ជូរចត់ ជាពិសេសរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប៉ុន្តែមកដល់ទសវត្សរ៍១៩៨០ ការវាយប្រយុទ្ធគ្នានៅតែបន្ត ហើយបានដាក់កម្ពុជាឱ្យនៅដាច់ដោយឡែកពីសហគមន៍អន្តរជាតិ។ វិស័យសំខាន់ៗរបស់ប្រទេសដូចជា សេដ្ឋកិច្ច សង្គមកិច្ច អប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លាញចោលស្ទើរគ្មានសល់។ ក្នុងរយៈពេលនោះ ប្រជាជននិងកុមាររាប់លាននាក់ត្រូវបានកាប់សម្លាប់ ធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ បង្ខំឱ្យធ្វើការធ្ងន់ធ្ងរ ទទួលអាហារមិនបានគ្រប់គ្រាន់ រស់នៅមិនសមរម្យ និងធ្វើឱ្យប្រទេសកម្ពុជាបិតនៅដាច់ចេញពីសហគមន៍អន្តរជាតិ។

កម្ពុជាបានចាប់ផ្តើមការអភិវឌ្ឍរបស់ខ្លួនចេញពីចំណុចសូន្យ។ នៅឆ្នាំ១៩៩០ រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងនិងប្តេជ្ញាចិត្តអភិវឌ្ឍប្រទេសលើគ្រប់វិស័យ ដើម្បីឱ្យប្រជាជននិងកុមាររួចផុតពីភាពក្រីក្រ។ លទ្ធផលសង្ខេបបង្ហាញនៅក្នុងប្រអប់១.១ខាងក្រោម៖

**ប្រអប់ ១.១- ការអភិវឌ្ឍប្រទេសកម្ពុជាក្រោយឆ្នាំ១៩៩០**

សេដ្ឋកិច្ចកម្ពុជាបានកើនឡើងជាមធ្យមប្រមាណ ៧% នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ហើយផលិតផលក្នុងស្រុកបានកើនឡើងជាង១០០០ដុល្លារក្នុងម្នាក់នៅឆ្នាំ២០១៣ បើប្រៀបធៀបកាលពីមួយទសវត្សរ៍មុនគឺ ទទួលបានតិចជាង២០០ដុល្លារក្នុងម្នាក់។ អត្រានៃភាពក្រីក្រសម្រេចបានជាងពាក់កណ្តាលនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ទីផ្សារការងារមានការកើនឡើងនៅទីប្រជុំជន ចំណែកការងារប្រកបផលិតផលកសិកម្មក៏មានការកើនឡើងដែរ។ សព្វថ្ងៃ កម្ពុជាបាននាំស្បៀងចេញទៅក្រៅប្រទេស បើប្រៀបធៀបទៅនឹងទសវត្សរ៍មុនៗកម្ពុជាជាប្រទេសដែលនាំចូលស្បៀងអាហារពីបរទេស។ អក្ខរភាពនិងការសិក្សាអប់រំមានការកើនឡើងយ៉ាងឆាប់រហ័ស អត្រានៃអក្ខរភាពគឺមានកម្រិតខ្ពស់ក្នុងចំណោមប្រទេសដែលស្ថិតនៅក្នុងប្រទេសដែលមានការអភិវឌ្ឍនៅមានកម្រិត។ ដូចគ្នានេះដែរ អត្រាមរណភាពនៃទារកនិងមាតាមានការថយចុះ ហើយអាយុកាលនៃជីវិតរស់នៅមានការកើនឡើងខ្ពស់។

ការបោះឆ្នោតជាតិប្រកបដោយប្រជាធិបតេយ្យ បានរៀបចំឡើងដោយរាជរដ្ឋាភិបាលកម្ពុជាបានចំនួន៥លើកនិងថ្នាក់ឃុំសង្កាត់ចំនួន៣លើក ប្រកបដោយភាពជោគជ័យ។ ដំណើរការនៃប្រជាធិបតេយ្យនៅកម្ពុជា គឺប្រកបដោយភាពរឹងមាំល្អ ទោះបីយ៉ាងណា កម្ពុជានៅមានភាពប្រឈមផ្សេងៗជាច្រើន ដូចជាហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ថវិកា និងសមត្ថភាពស្ថាប័ន ដែលទាមទារឱ្យមានការពង្រឹងបន្ថែមទៀត។ នៅឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលជាយុទ្ធសាស្ត្រស្នូលមួយសម្រាប់អភិវឌ្ឍប្រទេសពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ត្រូវបានដាក់ចេញនៅឆ្នាំ២០១៤ ដើម្បីធ្វើការអនុវត្ត។

ទោះបីគោលនយោបាយនិងកម្មវិធីជាតិបាននិងកំពុងដំណើរការល្អគួរឱ្យកត់សម្គាល់ក៏ដោយ ក៏កម្ពុជានៅមានភាពប្រឈមនឹងបញ្ហាជាច្រើនដូចជា កង្វះខាតប្រព័ន្ធគាំពារសង្គម សុខភាព ការអប់រំ ជាពិសេសនៅតាមតំបន់ជនបទ។ លើសពីនេះ នៅមានបញ្ហាផ្សេងៗទៀតដែលកើតមានឡើងដោយថាហេតុនៅក្នុងតំបន់និងលើសកលលោក ដូចជាគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ បញ្ហាសេដ្ឋកិច្ចសកលលោក បញ្ហាភេរវកម្ម និងវិសមភាពចំណូល។ល។ ហេតុទាំងនេះជាកត្តាប្រឈមដ៏សំខាន់ដែលប៉ះពាល់ដល់កុមារ ពិសេសក្នុងចំណោមកុមារងាយរងគ្រោះ ដែលបណ្តាលឱ្យមានពលកម្មកុមារ កុមារកំព្រា កុមារអនាថា ការជួញដូរកុមារ និងកុមារប្រព្រឹត្តល្មើសនឹងច្បាប់ជាដើម ដែលបណ្តាលឱ្យមានវដ្តនៃភាពក្រីក្រនិងជាកត្តាបង្អាក់ដំណើរនៃការអភិវឌ្ឍមូលធនមនុស្ស សេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមកិច្ចសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

ដូច្នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមាររយៈពេល ៣ឆ្នាំ **២០១៦-២០១៨** ដើម្បីកៀរគរធនធាន ខិតខំប្រឹងប្រែងដោះស្រាយបញ្ហាកុមារនៅកម្ពុជា ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ស្របនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះកុមារ សំដៅអនុវត្តអនុសាសន៍នានារបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។

នេះជាផែនការសកម្មភាពជាតិលើកទីមួយ ជាផែនទីបង្ហាញផ្លូវ និងជាផែនការគោលសម្រាប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំនិងអនុវត្តកម្មវិធីដែលផ្តោតលើកុមារ ក្នុងការរួមចំណែកសម្រេចឱ្យបានចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ក៏បានបង្ហាញអំពីតួនាទីនិងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និងកុមារខ្លួនឯងក្នុងការចូលរួមសម្រេចឱ្យបាននូវការកែលម្អការរស់នៅរបស់កុមារកម្ពុជា ដើម្បីទទួលបានសិទ្ធិនិងឱកាសស្មើភាពគ្នាសម្រាប់ការរីកលូតលាស់ និងការអភិវឌ្ឍដោយមានសុខដុមនីយកម្ម។

**ប្រអប់ទី១.២- សម្រង់អនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ឆ្នាំ២០១១**

១- ពង្រឹងគុណភាពអប់រំ (អប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ) ដល់កុមារ

២- ផ្តល់ការបណ្តុះបណ្តាលដល់អ្នកថែទាំកុមារ មន្ត្រីអនុវត្តច្បាប់ គ្រូបង្រៀនជាដើមស្តីពីសិទ្ធិកុមារ សេវាផ្នែកច្បាប់ និងសេវាផ្សព្វផ្សាយ

៣- ពង្រីកការផ្តល់សេវាសុខភាពដល់កុមារទាំងអស់ (រួមទាំងការការពារការឆ្លងមេរោគអេដស៍/ជំងឺអេដស៍)

៤- ពង្រឹងការអនុវត្តច្បាប់លើការធ្វើអាជីវកម្មពាក់ព័ន្ធនឹងសិទ្ធិកុមារ និងពលកម្មកុមារ ជាពិសេសក្នុងទម្រង់ធ្ងន់ធ្ងរ

៥- ពង្រឹងដំណើរការត្រួតពិនិត្យតាមដាននិងវាយតម្លៃ និងបង្កើតប្រព័ន្ធទិន្នន័យស្តីពីកុមារ

៦- ពង្រឹងយន្តការសម្រាប់ការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ

៧- ជួយសង្គ្រោះកុមារពីគ្រោះថ្នាក់ អំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការឃុំឃាំង និងអំពើហិង្សាផ្សេងៗ

៨- ធានាពីភាពមិនរើសអើងប្រឆាំងនឹងកុមារពិការ

៩- ពង្រឹងការថែទាំកុមារនៅក្នុងសហគមន៍ និងការពារកុមារតាមចិញ្ចឹមថ្មល់

១០- ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជាពិសេសការជួញដូរកុមារ

១១- ការការពារកុមារតាមម្តាយក្នុងពន្ធនាគារ

១២- បញ្ឈប់ការជម្លៀសប្រជាជនពីដីរបស់ពួកគាត់ និងពង្រីកជំនួយរូបវន្តដល់ប្រជាជនក្រីក្រ ដើម្បីការពារកូនរបស់ពួកគេ

១៣- ពង្រីកការចុះបញ្ជីកំណើត

១៤- ផ្តល់ការយកចិត្តទុកដាក់ពិសេសដល់កុមារក្នុងសហគមន៍ជនជាតិដើមភាគតិច និង

១៥- បន្ថែមថវិកាសម្រាប់ការងារកុមារ និងពង្រឹងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រភព. របាយការណ៍ដាក់ជូនដោយរដ្ឋជាភាគីក្រោមមាត្រា៤៤ នៃអនុសញ្ញាលើសេចក្តីសន្និដ្ឋានកម្ពុជារបស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ កិច្ចប្រជុំលើកទី៥៧ ថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។

## ១.១- គោលនយោបាយចំពោះកុមារ

ដើម្បីអភិវឌ្ឍកុមារក្នុងចក្ខុវិស័យមួយដែលត្រូវមានការធានាច្បាស់លាស់សម្រាប់អនាគតកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ជាអាទិ៍ដូចខាងក្រោម៖

### ១.១.១- ក្របខ័ណ្ឌជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៨ ចែងថា "រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំនិងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ"។
- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលជាក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ បានកំណត់ច្បាស់លាស់ពីលទ្ធផលរំពឹងទុកនិងសូចនាករសម្រាប់កុមារ។
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា បានផ្តោតលើបង្កើនការងារសមធម៌និងប្រសិទ្ធភាព និងការទទួលស្គាល់កុមារជាឆ្អឹងខ្នងនៃធនធានមនុស្សនិងសេដ្ឋកិច្ចរបស់ប្រទេសជាតិ៖
  - ការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ : ការបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលសំដៅលើកកម្ពស់សុខុមាលភាពនិងអាហារូបត្ថម្ភរបស់ប្រជាជនទូទៅ កាត់បន្ថយអត្រាស្លាប់មាតា ទារក និងកុមារ តាមរយៈការពង្រឹងនិងពង្រីកសេវាសុខាភិបាលប្រកបដោយគុណភាព ប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។
  - ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម : ពង្រឹងប្រព័ន្ធគាំពារ និងបង្កើតឱ្យមានប្រព័ន្ធគាំពារសង្គមផ្លូវការមួយគឺយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ សំដៅគាំពារជនក្រីក្រនិងងាយរងគ្រោះ ដែលត្រូវសម្រេចសមិទ្ធផលសំខាន់ៗតាមរយៈកម្មវិធីចែកស្បៀងដល់ជនក្រីក្រ កម្មវិធីស្បៀងពលកម្ម កម្មវិធីគាំពារកុមារក្រីក្រឱ្យបានចូលរៀន និងការជួយឧបត្ថម្ភគាំទ្រជនក្រីក្រនិងជនងាយរងគ្រោះ។
- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥នៃរដ្ឋសភា : បន្តផ្តល់អាទិភាពលើការអភិវឌ្ឍសុខុមាលភាពកុមារឱ្យបានល្អប្រសើរ ដោយជំរុញការផ្សព្វផ្សាយនិងអនុវត្តយ៉ាងហ្មត់ចត់នូវអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ពិសេសធានាឱ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារគឺ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ : សិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីជាច្រើនរបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលនៅតែបន្តយ៉ាងមុតមាំក្នុងការបង្កើតនិងអនុវត្តប្រព័ន្ធសុវត្ថិភាពសង្គមមួយដែលមានលក្ខណៈទូលំទូលាយ មានចីរភាពក្នុងគោលបំណងគាំពារជីវភាពរស់នៅរបស់ជនក្រីក្រនិងជនងាយរងគ្រោះ។

- យុទ្ធសាស្ត្រជាតិគាំពារសង្គម (២០១១) បានចែងយ៉ាងច្បាស់ពីបញ្ញត្តិនិងការគាំទ្រសម្រាប់កុមារនិងយុវជន ជាពិសេសកុមារនិងយុវជនដែលងាយរងគ្រោះដោយសារពលកម្មកុមារ ការជួញដូរកុមារ ការធ្វើចំណាកស្រុក កុមារដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ កុមារអនាថា កុមារជនជាតិដើមភាគតិច កុមារកំព្រា និងកុមារមានផ្ទុកមេរោគអេដស៍ ដែលអាចចាត់ទុកថា "ក្រុមកុមារដែលបាត់បង់ឱកាស"។
- គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ត្រូវបានដាក់ចេញនាខែឧសភា ឆ្នាំ២០១០ ដែលជាក្របខ័ណ្ឌមូលដ្ឋានចម្បងមួយសម្រាប់រៀបចំកម្មវិធីកុមារ។ គោលនយោបាយនេះបានប្តេជ្ញាចិត្តធានាថាគ្រប់ភូមិឃុំឱ្យមានសុវត្ថិភាព ដោយពុំមានចោរកម្មនិងអំពើប្លន់គ្រប់ប្រភេទ ពុំមានការផលិត ការចែកចាយនិងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់គ្រប់ប្រភេទ ពុំមានសកម្មភាពអបាយមុខ ការជួញដូរផ្លូវភេទលើស្ត្រីនិងកុមារ និងអំពើហិង្សា ពុំមានការលេងល្បែងស៊ីសងខុសច្បាប់ ការប្រើប្រាស់អាវុធខុសច្បាប់ និងសកម្មភាពខុសច្បាប់ផ្សេងៗទៀត។

## ១.១.២- ក្របខ័ណ្ឌអន្តរជាតិ

បន្ថែមលើក្របខ័ណ្ឌគតិយុត្តជាតិជាធរមាន ក្នុងស្មារតីយកចិត្តទុកដាក់ការពារសិទ្ធិកុមារ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងពិធីសារអន្តរជាតិជាច្រើន។ ជាមួយគ្នានេះដែរ ក្នុងនាមជារដ្ឋសមាជិករបស់អង្គការសហប្រជាជាតិ កម្ពុជាត្រូវបានភ្ជាប់កាតព្វកិច្ចនៅក្នុងសេចក្តីសម្រេចទាំងឡាយរបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងកុមារ។ សន្ធិសញ្ញា និងសេចក្តីប្រកាសសំខាន់ៗដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នមាន៖

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៩២
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ឆ្នាំ២០០៧
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាមនិងសកម្មភាពបន្ទាប់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០០៥
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ១៣៨<br>ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការងារ ឆ្នាំ១៩៩៩
- អនុសញ្ញារបស់អង្គការអន្តរជាតិខាងការងារលេខ២៨ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ច ឆ្នាំ១៩៧០
- ពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ នៅឆ្នាំ២០០២
- ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ នៅឆ្នាំ២០០២

ដោយឡែក ក្នុងក្របខ័ណ្ឌសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ព្រះរាជាណាចក្រកម្ពុជាក៏បានចុះហត្ថលេខាលើសេចក្តីប្រកាស និងការប្តេជ្ញាចិត្តរបស់អាស៊ានស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារ និងលិខិតូបករណ៍របស់អាស៊ានដទៃទៀតសម្រាប់ការលើកកម្ពស់និងការពារសិទ្ធិកុមារ។

# ១.២- ការវិភាគស្ថានភាពកុមារ

## ១.២.១- អក្ខរភាពនិងការសិក្សា

**អក្ខរភាព** : របាយការណ៍អង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០១៣ បង្ហាញថាអត្រាអក្ខរភាពក្នុងចំណោមកុមារអាយុពី៦-១៧ឆ្នាំ មានប្រមាណ៨៣,៤%។ កុមារអាយុពី១០-១៧ឆ្នាំ មានប្រមាណ៩០,៣% ក្នុងនោះមានកុមារប្រមាណ៩,៧% ស្មើនឹង២៤៣ ៩៥០នាក់ មិនចេះអាន និងមិនទទួលបានការសិក្សាអប់រំក្នុងជីវិតរបស់ពួកគេ។ បន្ថែមលើនេះ ភាពខុសគ្នាអំពីយេនឌ័រមិនទាន់មានការបែងចែកជាក់លាក់ នៅក្នុងអត្រានៃអក្ខរភាពនេះនៅឡើយទេ។

**កុមារនិងការសិក្សា** : តាមរបាយការណ៍ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ បានរាយការណ៍ថាមានសាលាមត្តេយ្យសិក្សាសរុបចំនួន២ ៨១៣សាលា និងមានសិស្សចុះឈ្មោះចូលរៀនប្រមាណ១២៨ ២៥៧នាក់ នៅឆ្នាំ២០១២-២០១៣ ពាក់កណ្តាលនៃកុមារទាំងនេះគឺជាកុមារី។ នៅក្នុងចំនួននេះមានប្រហែល៥៦%នៃចំនួនកុមារសរុប គឺជាកុមារដែលមានក្រុមអាយុ៥ឆ្នាំ ហើយក្នុងនោះប្រមាណ២១% គឺកុមារដែលមានក្រុមអាយុពី៣-៤ឆ្នាំ និង៣% គឺជាកុមារដែលមានក្រុមអាយុពី០-៣ឆ្នាំ។ កម្មវិធីអប់រំកុមារតូចនៅក្នុងសាលារដ្ឋបានផ្តល់នូវអាហារូបត្ថម្ភជាច្រើន។ អត្រាចុះឈ្មោះចូលរៀនពិតក្នុងឆ្នាំសិក្សា២០១២-២០១៣ នៅកម្រិតបឋមសិក្សាគឺប្រមាណ៩៧% ហើយមិនមានភាពខុសគ្នាពីយេនឌ័រនោះទេ។ អត្រាបញ្ចប់ការសិក្សាបានធ្លាក់ចុះមកនៅត្រឹម៨៧%(សម្រាប់កុមារទាំងពីរភេទ)។ ជាមួយនេះដែរ អត្រាការចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យមានការធ្លាក់ចុះយ៉ាងខ្លាំង ដែលមានប្រមាណតែ៥៤% ប៉ុណ្ណោះ ហើយអត្រាបញ្ចប់ថ្នាក់អនុវិទ្យាល័យបានត្រឹមតែ៤៤%។ រីឯការអង្កេតសេដ្ឋកិច្ចសង្គមក៏បានរាយការណ៍ថា អត្រាកុមារអាយុពី ៦-១៧ ឆ្នាំដែលបញ្ចប់ការសិក្សាអប់រំគឺមាន៧៩,១% (៧៨,៦% គឺជាកុមារី និង៧៩,៤% គឺជាកុមារាតាមទិន្នន័យ ឆ្នាំ២០១២)។

**មធ្យមភាគនៃឆ្នាំសិក្សា** : អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១២ បង្ហាញថា ចំនួនឆ្នាំសិក្សាជាមធ្យមសម្រាប់ក្រុមអាយុ៦-២៤ឆ្នាំ គឺ៥,២៤ឆ្នាំ (៥,៣២ឆ្នាំ សម្រាប់កុមារា និង៥,១៥ឆ្នាំ សម្រាប់កុមារី) ក្នុងឆ្នាំ២០១២។ សម្រាប់ការបែងចែកឆ្នាំនៃការសិក្សាតាមតំបន់ រាជធានីភ្នំពេញ៧,៣ឆ្នាំ ប្រជុំជន៦,០ឆ្នាំ និងជនបទ៤,៩ឆ្នាំ។ កុមារអាយុ ៦-១៧ឆ្នាំ ដែលបានចូលសិក្សាមានចំនួន៩៣%(កុមារា៩១,១% និងកុមារី៩៣,៩%)។

**តារាង ២.១- បន្ទុប្បន្នកម្មកុមារចុះឈ្មោះចូលរៀន កុមារដែលអាចអាននិងសរសេរបាន និងមធ្យមភាគនៃឆ្នាំសិក្សា តាមក្រុមចំណូល (និងចំណាយ)**

| ក្រុមចំណូល (ចំណាយ) | % កុមារចុះឈ្មោះចូលរៀន បន្ទុប្បន្ន (១០-១៧ឆ្នាំ) | % កុមារដែលអាចអាន និងសរសេរបាន(១០-១៧ឆ្នាំ) | មធ្យមភាគនៃឆ្នាំសិក្សា |
|---|---|---|---|
| ទាបបំផុត ២៥% | ៧១ | ៧៨,៣ | ៣,៧ |
| ២៥%-៥០% | ៧២ | ៨៩,២ | ៤,៦ |
| ៥០%-៧៥% | ៨២ | ៩៣,៥ | ៥,៤ |
| ខ្ពស់បំផុត ២៥% | ៨៧ | ៩៥,៥ | ៦,៩ |
| **សរុប** | ៧៨ | ៨៩ | ៥,២ |
| កុមារា | ៧៩ | ៨៨,៧ | ៥,៣ |
| កុមារី | ៧៨ | ៩០,២ | ៥,១ |

ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១២

**ហេដ្ឋារចនាសម្ព័ន្ធអប់រំ** : ចម្ងាយពីផ្ទះទៅសាលារៀនក៏ជាកត្តាប៉ះពាល់ដល់ការចុះឈ្មោះចូលរៀនរបស់កុមារ។ សាលាបឋមសិក្សាសរុបមានចំនួន៦ ៩១០ ហើយចម្ងាយជាមធ្យមពីភូមិទៅសាលាបឋមសិក្សាគឺ១,២គ.ម. ចំណែកអនុវិទ្យាល័យមានចំនួន ១ ៦២២ និងមានចម្ងាយជាមធ្យមពីភូមិចំនួន៥,២គ.ម. វិទ្យាល័យមានចំនួន៤៣៣។ ចម្ងាយពីសាលារៀនកាន់តែឆ្ងាយ ការបោះបង់ចោលការសិក្សាកាន់តែច្រើន ពិសេសនៅរដូវភ្លៀងដោយសារផ្លូវខូចបង្កការលំបាកសម្រាប់កុមារតូចៗធ្វើដំណើរទៅសាលារៀន។ កុមារបោះបង់ការសិក្សាប្រមាណជាង៣៣% នៅពេលបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា ដោយសារចម្ងាយផ្លូវពីភូមិទៅអនុវិទ្យាល័យកាន់តែឆ្ងាយ។ ហេដ្ឋារចនាសម្ព័ន្ធអប់រំរបស់ខេត្តនីមួយៗ ពិសេសសាលាស្ថិតនៅខេត្តភាគខាងជើង ភាគពាយព្យ ភាគឦសាន និងភាគនិរតីមានចម្ងាយឆ្ងាយជាងខេត្តនៅភាគខាងត្បូងនិងភាគអាគ្នេយ៍។

**ការសិក្សារបស់កុមារពិការ** : យើងមានសាលារៀនចំនួន១៧០ សម្រាប់សិស្សពិការគ្រប់ប្រភេទ។ កុមារពិការចំនួន ១៩ ៥៩៦នាក់ កុមារីចំនួន ៩ ៣៤២នាក់ ចូលរៀនក្នុងឆ្នាំសិក្សា២០១២-២០១៣។ មានកុមារពិការច្រើនជាង ៤២ ០០០នាក់ អាយុពី ៦-១៧ឆ្នាំ ហើយចំនួនតិចជាងពាក់កណ្តាលបានចូលរៀន (ទិន្នន័យអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជា)។

**ការបណ្តុះបណ្តាលវិជ្ជាជីវៈ** : តាមរបាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រព័ន្ធបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈបង្ហាញថា ក្នុងឆ្នាំ២០១១-២០១២ មានសិក្ខាកាមចំនួន១២៨ ៥៥៩នាក់ (ស្រីចំនួន ៦៥ ១០១នាក់) ទទួលបានការបណ្តុះបណ្តាលក្នុង៣៣១ស្ថាប័ន (ដោយមានគ្រឹះស្ថានសាធារណៈចំនួន៥៤ ក្រសួង ៤ មានក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា) គ្រឹះស្ថានឯកជនចំនួន២២៨ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៤៩។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកម្មវិធីសិក្សានិងធ្វើតេស្តស្តង់ដា និងបានការវាយតម្លៃអំពីគុណភាព និងសារប្រយោជន៍របស់វគ្គបណ្តុះបណ្តាលទាំងនោះ។

**តម្លៃសិក្សា** : គោលការណ៍មូលដ្ឋាននៃការសិក្សាថ្នាក់បឋមសិក្សាគឺការសិក្សាដោយឥតបង់ថ្លៃ ប៉ុន្តែជាក់ស្តែងគ្រួសារត្រូវចំណាយផ្ទាល់ខ្លួនសម្រាប់ការសិក្សាគ្រប់កម្រិត ហើយតម្លៃត្រូវកើនឡើងជាលំដាប់តាមកម្រិតថ្នាក់។ តម្លៃសិក្សានេះជាកត្តាប្រឈមចំពោះកុមារដែលមកពីគ្រួសារក្រីក្រ មិនអាចមានលទ្ធភាពបន្តការសិក្សាតទៅទៀតបាន។ ការធ្វើឱ្យសម្រេចបាននូវគ្រប់សូចនាករទាំងអស់នៃការសិក្សាអប់រំ មានភាពផុយស្រួយទាក់ទងទៅនឹងប្រាក់ចំណូល។ កុមារមកពីគ្រួសារមានប្រាក់ចំណូលតិច មានការចុះឈ្មោះចូលរៀនកាន់តែតិច។

**តារាង ២.២- តម្លៃសិក្សាប្រចាំឆ្នាំជាមធ្យមសម្រាប់មួយគ្រួសារ ឆ្នាំ២០១២**

| កម្រិតនៃការអប់រំ | តម្លៃ(ពាន់៛) |
|---|---|
| សាលាមត្តេយ្យ | ១៩៤ |
| បឋមសិក្សា | ២៧៣ |
| អនុវិទ្យាល័យ | ៥៦៦ |
| វិទ្យាល័យ | ១ ០២០ |
| បណ្តុះបណ្តាលជំនាញ | ៣ ៦០៤ |
| សាកលវិទ្យាល័យ | ៣ ៥០៨ |
| មធ្យម | ៦២១ |

ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១២



២

## ១.២.២- ជីវភាពរស់នៅ សុខភាព និងផ្ទះ

**ជីវភាពរស់នៅ** : អត្រាភាពក្រីក្រនៅកម្ពុជាបានថយចុះពី៤៧,៨% ក្នុងឆ្នាំ២០០៧ មក១៨,៩% ក្នុងឆ្នាំ២០១២។ សន្តិសុខស្បៀងត្រូវបានកែលម្អក្នុងកំឡុងទសវត្សរ៍ចុងក្រោយ ដោយសារកង្វះស្បៀងនៅតិចត្រឹមតែជាង៥% សម្រាប់ប្រជាជនសរុបក្នុងឆ្នាំ២០១២។ ប្រទេសកម្ពុជាមានស្រូវអង្ករគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងប្រទេស និងសម្រាប់នាំចេញ។ ទោះជាមានចំនួនប្រជាជនជាច្រើនផ្តុំគ្នានៅក្បែរបន្ទាត់ភាពក្រីក្រ ក៏ពួកគេមិនមែនស្ថិតក្នុងភាពក្រីក្រដែរ តាមបច្ចេកទេសគឺពួកគាត់គ្រាន់តែងាយរងគ្រោះ។ ក្នុងន័យនេះ ប្រសិនបើកំណត់ចំណូលរបស់ប្រជាជនតាមលំដាប់ថ្នាក់នោះ ប្រជាជនដែលមានចំណាត់ថ្នាក់ស្ថិតនៅក្នុងក្រុមទទួលបានប្រាក់ចំណូលទាបពី៣០% ទៅ៤០% ជាចំណាត់ថ្នាក់ក្រុមងាយរងគ្រោះ។ ភាពក្រីក្ររបស់កុមារមានន័យថា ភាពក្រីក្ររបស់កុមារក្នុងចំណោមកុមារអាយុក្រោម១៨ឆ្នាំ មានអត្រាខ្ពស់ជាងអត្រាសរុបនៃភាពក្រីក្រនៅទូទាំងប្រទេស ព្រោះថាគ្រួសារក្រីក្រមានអត្រាផ្តល់កំណើតសរុបខ្ពស់និងមានកូនច្រើន។ យោងតាមអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១២ នៅកម្ពុជាអត្រាភាពក្រីក្រកុមារមាន២៤%។

| តារាង ២.៣- ការបែងចែកវាងមនុស្សពេញវ័យនិងកុមារ (អាយុ ០-១៧ឆ្នាំ) តាមក្រុមចំណូល (ចំណាយ) | | |
|---|---|---|
| ចំណាត់ថ្នាក់ចំណូល | % គ្រប់មនុស្ស | % កុមារ |
| ≤ ២៥% | ៣០,១ | ៣៦ |
| ២៥-៥០% | ២៨,២ | ២៩,៤ |
| ៥០%-៧៥% | ២៣,៩ | ២១,៨ |
| ៧៥%-១០០% | ១៧ | ១២,៨ |

ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១២

សមាមាត្រប្រជាជនក្រីក្រនៅតាមជនបទមានទំហំធំធេង។ គ្រួសារកសិករដែលមានធនធានតិចតួច មានផលិតផលកសិកម្មទាប។ ការងារពាក់ព័ន្ធនឹងវិស័យកសិកម្មមានទំហំតូចតាច ហើយពួកគេពុំមានលទ្ធភាពទទួលអនុផលព្រៃឈើនិងផលនេសាទឱ្យបានគ្រប់គ្រាន់។ បម្រែបម្រួលអាកាសធាតុនិងបញ្ហាដីធ្លីក៏បណ្តាលឱ្យជីវភាពរបស់ប្រជាជនកាន់តែលំបាក។

**សុខភាព** : តាមរបាយការណ៍ប្រព័ន្ធព័ត៌មានគ្រប់គ្រងវិស័យសុខាភិបាល បានបង្ហាញពីការថយចុះអត្រាមរណកុមារក្រោមអាយុ១ឆ្នាំពី៤៥នាក់ មកនៅត្រឹម២៨ ក្នុង១០០០កំណើតរស់ និងកុមារក្រោមអាយុ៥ឆ្នាំ មានការថយចុះពី៥៤ ទៅ ៣៥ ក្នុងឆ្នាំ២០១០ និងឆ្នាំ២០១៤។ តាមរយៈរបាយការណ៍ក៏បានបង្ហាញពីភាពប្រសើរឡើងលើការកាត់បន្ថយមរណភាពកុមារ កុមារកង្វះអាហារូបត្ថម្ភក៏ត្រូវបានកាត់បន្ថយដែរ។ កុមារដែលមានទម្ងន់ខ្វះគីឡូមានអាយុពី ០-៥ឆ្នាំ ត្រូវបានកាត់បន្ថយពី២៨% មកនៅត្រឹម២៣% ហើយកុមារក្រិសក្រិនត្រូវបានកាត់បន្ថយពី៤០% មកនៅត្រឹម ៣២% រវាងឆ្នាំ២០១០ និងឆ្នាំ២០១៤។ ក្នុងស្ថានភាពរួមនេះ កុមារកង្វះអាហារូបត្ថម្ភមានភាពផ្សេងៗពីគ្នាទៅតាមតំបន់ និងទៅតាមសង្គមមនុស្ស។ កុមារដែលជាគ្រួសារនៅតាមជនបទក្រីក្រ ហើយមិនមានការសិក្សាអប់រំ បញ្ហាកង្វះអាហារូបត្ថម្ភមានកម្រិតខ្ពស់ជាងកុមារដែលជាគ្រួសារមានជីវភាពធូរធារនៅទីប្រជុំជន និងមានការសិក្សាអប់រំ។

យោងតាមទិន្នន័យឃុំ សង្កាត់បង្ហាញថា ចម្ងាយជាមធ្យមពីមណ្ឌលសុខភាពទៅភូមិមានប្រវែងប្រមាណ ៥,៤ គីឡូម៉ែត្រ ដែលជាចម្ងាយឆ្ងាយ ហើយផ្លូវមានការលំបាកធ្វើដំណើរ។ រីឯការចុះបញ្ជីកំណើតកុមារ គឺមានអត្រាប្រមាណ៦២,២% នៃកុមារទាំងអស់ក្នុងឆ្នាំ២០១០។

**ទីជម្រក** : តាមរបាយការណ៍អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ បង្ហាញថា ផ្ទះឬទីជម្រកដែលធ្វើអំពីឫស្សីប្រក់ស្បូវមានប្រមាណ៩% ហើយប្រមាណ២៥%នៃខ្ទង់ផ្ទះដែលមានជញ្ជាំង និង៦%ផ្ទះធ្វើអំពីរនាប

ភាគច្រើននៅតាមតំបន់ជនបទ បើធៀបទៅនឹងតំបន់ប្រជុំជន។ ភាពគ្មានផ្ទះសម្បែងមិនមានបញ្ហាទេនៅប្រទេសកម្ពុជា ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនដែលរស់នៅទីប្រជុំជនបានប្រឈមនឹងបញ្ហាពីរធំៗ គឺការកើនឡើងនៃពាណិជ្ជនីយកម្ម និងការកើនឡើងនៃការធ្វើចំណាកស្រុកដែលប៉ះពាល់ដល់ដីធ្លីនិងការរស់នៅក្នុងទីប្រជុំជន។

**ទឹកនិងបញ្ហាអនាម័យ** : តាមការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៣ បង្ហាញថាប្រមាណ៤៩,៧% នៃគ្រួសារទាំងអស់ទទួលបានទឹកស្អាតប្រើប្រាស់ក្នុងរដូវវស្សា ហើយមានកើនឡើងដល់ ៥៨,៧% ក្នុងរដូវប្រាំង ព្រោះនៅក្នុងរដូវវស្សា ប្រភពទឹកស្អាតមួយចំនួនមានជាតិពុលដោយសារទឹកជំនន់ឬការលាយបញ្ចូលគ្នារវាងទឹកស្អាតជាមួយទឹកដែលបង្ហូរចេញពីលូ។ គ្រួសារប្រមាណ៥១,៧% ប្រើប្រាស់បង្គន់អនាម័យ ដោយឡែកគ្រួសារនៅជនបទទទួលបានការប្រើប្រាស់បង្គន់អនាម័យតែ៤០,២% ប៉ុណ្ណោះ។ ការមិនទទួលបានទឹកស្អាតនិងអនាម័យ គឺបានបង្កបញ្ហាជាច្រើនដល់សុខភាព ជាពិសេសចំពោះកុមារនិងការបាត់បង់ចំណូល។

| **ប្រអប់ ២.២- ភាពចាំបាច់នៃអនាម័យ** |
|---|
| នៅពេលប្រជាជនបន្ទោរបង់នៅតាមទីវាលពាសវាលពាសកាល មេរោគនិងពពួកសត្វល្អិតដែលនៅក្នុងលាមកអាចឆ្លងមកមនុស្សវិញ ដែលបង្កទៅជាជំងឺឆ្លងផ្សេងៗ ជាពិសេសជំងឺរាក ជំងឺរលាកផ្លូវដង្ហើម ជំងឺដង្កូវព្រូនក្នុងពោះវៀន ជំងឺគ្រិសគ្រិនជាដើម ដែលជាមូលហេតុចម្បងនៃមរណភាពរបស់កុមារ។ ការប្រតិបត្តិអនាម័យល្អ មានសារៈសំខាន់ចំពោះកិច្ចការពារនិងថែទាំសុខភាពគ្រួសារនិងសហគមន៍ទាំងមូល។ |

## ១.២.៣- កុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការ

នៅកម្ពុជាមិនទាន់មានទិន្នន័យជាក់លាក់ស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការទេ តែផែនការយុទ្ធសាស្ត្រជាតិស្តីពីកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការ បានប៉ាន់ស្មានថា មានកុមារងាយរងគ្រោះប្រមាណ១៤%នៃចំនួនកុមារសរុប។ តាមទិន្នន័យឃុំសង្កាត់ឆ្នាំ២០១២ គេប៉ាន់ប្រមាណថាមានកុមារកំព្រាប្រមាណ ៦២ ៣៣៤នាក់ ហើយកុមារទាំងអស់នោះប្រមាណ២០% មានចំនួនតិចជាង១៣ ០០០នាក់ រស់នៅដាច់ដោយឡែកពីគ្រួសារឬអាណាព្យាបាល។

ទិន្នន័យអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១៣ បង្ហាញថា មានកុមារពិការប្រមាណ១% នៃចំនួនកុមារទូទាំងប្រទេស។ តួលេខនេះមានកម្រិតទាប ព្រោះថា ចំនួននៃកុមារពិការមិនបានប្រមូលទិន្នន័យជាក់លាក់ពីភ្នាក់ងារប្រមូលទិន្នន័យ។ ម្យ៉ាងវិញទៀត កុមារពិការ គឺជាក្រុមដែលងាយរងគ្រោះ ហើយមានកម្រិតក្នុងការទទួលបានសេវាកម្មនានាពីសង្គម ពួកគេខ្លះប្រឈមនឹងការរើសអើង និងករណីខ្លះ ក៏មានអំពើហិង្សាពីគ្រួសារផងដែរ។

ចំណុចផ្តើម គឺត្រូវឱ្យមានតួលេខជាក់លាក់នៃកុមារកំព្រា កុមារងាយរងគ្រោះ និងកុមារពិការសិនមុននឹងបង្កើតកម្មវិធីអន្តរាគមន៍ឱ្យបានត្រឹមត្រូវ។

ការសិក្សាតាមមូលដ្ឋាន រៀបចំដោយអង្គការភ្លែនអន្តរជាតិ (កុមារងាយរងគ្រោះ និងកុមារដែលបាត់បង់ឱកាសក្នុងការទទួលបានការរៀនសូត្រ និងការចូលរួមក្នុងសាលាភ្នំពេញឆ្នាំ២០១៤) បានបង្ហាញថា អគារសិក្សាសម្រាប់កុមារងាយរងគ្រោះមិនទទួលបានហិរញ្ញប្បទានគ្រប់គ្រាន់ គ្រូបង្រៀនត្រូវការប្រាក់បៀវត្សរ៍បន្ថែម និងតម្រូវការក្នុងការកំណត់ប្រភេទកុមារពិការ និងផ្តល់សេវាដល់កុមារទាំងនោះ។

## ១.២.៤- ការរំលោភបំពាន និងគ្រឿងញៀន

ការសិក្សាថ្មីៗនេះស្តីពីអំពើហិង្សាលើកុមារ ដែលរៀបចំដោយក្រសួងកិច្ចការនារី សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការ បង្ហាញថាប្រមាណ៦០% នៃកុមារអាយុក្រោម

១៧ឆ្នាំ ប្រឈមនឹងអំពើហិង្សាផ្នែករាងកាយ ហិង្សាផ្លូវភេទមានប្រមាណ៦,៤% ភាគច្រើនជាកុមារី។ ចំពោះគ្រឿងញៀន ទិន្នន័យឃុំ សង្កាត់ឆ្នាំ២០១២បង្ហាញថាមានតែប្រមាណ៣ ០០០គ្រួសារប៉ុណ្ណោះ ដែលបានរាយការណ៍ថាសមាជិកក្នុងគ្រួសារប្រើប្រាស់គ្រឿងញៀន។ ទោះជាយ៉ាងណាក្តី ភាពចាំបាច់គឺត្រូវរក្សាកុមារឱ្យឆ្ងាយពីការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន។ ចំណុចចាប់ផ្តើមគឺត្រូវមានភាពត្រឹមត្រូវ ហើយទិន្នន័យពាក់ព័ន្ធបញ្ហាកុមារប្រើប្រាស់គ្រឿងញៀនមានការពិបាក ព្រោះការសិក្សាស្រាវជ្រាវមានទំហំធំ ដូច្នេះការសិក្សាស្រាវជ្រាវតូចៗគឺមានភាពល្អប្រសើរជាង។

## ១.២.៥- ពលកម្មកុមារ កុមារអត់ចូលសាលានិងមិនធ្វើការងារ

អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១៣ ផ្អែកលើនិយមន័យទូទៅបង្ហាញថា សមាមាត្រនៃពលកម្មកុមារ សរុបមានប្រមាណ៩,៩% (ដោយមានកុមារាចំនួន៩,៣% និងកុមារីចំនួន១០,៧%) គិតជាចំនួនមានប្រមាណ៣៥៦ ៩៣២នាក់ ស្ថិតក្នុងកម្លាំងពលកម្មកុមារ។ ប៉ុន្តែ អង្កេតដែលធ្វើឡើងដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិនៅឆ្នាំ២០១២ បង្ហាញថា មានកុមារចំនួន១១% (ស្មើនឹង៤២៩ ៣៨០នាក់) ជាពលកម្មកុមារ។ តួលេខពីប្រភពទាំងពីរនេះមិនមានគម្លាតពីគ្នាច្រើនទេ របាយការណ៍ទាំងពីរបានកំណត់ប្រមាណ១០ ទៅ១១%។ សមាមាត្រពលកម្មកុមារនៅតំបន់ជនបទមានចំនួនខ្ពស់ប្រមាណ១១,៥% បើធៀបនឹងប្រជុំជនមានតែប្រមាណ៦,៥% តែប៉ុណ្ណោះ។ ភាគច្រើននៃពលកម្មកុមារ ធ្វើការងារក្នុងវិស័យកសិកម្ម និងសកម្មភាពពាក់ព័ន្ធ ដោយភាគច្រើនជួយការងារគ្រួសារដែលមិនទទួលបានប្រាក់កម្រៃ(មានចំនួនច្រើនជាង៧៥%)។ កុមារត្រូវបានគេទាញចូលក្នុងការងារស្រែចម្ការគ្រួសារនិងសន្តិសុខស្បៀង។ ការសន្និដ្ឋាន ពលករកុមារទាំងនោះ ត្រូវបានកំណត់ថាពួកគេត្រូវជួយជីវភាពគ្រួសារឱ្យមាននិរន្តរភាព។ សមាមាត្រពលកម្មកុមារធៀបនឹងចំនួនកុមារសរុបបានថយចុះយ៉ាងលឿនពីឆ្នាំ២០០៩-២០១៣ ប្រហែល២០% ក្នុងឆ្នាំ២០០៩ មកនៅត្រឹម៩,៩% ក្នុងឆ្នាំ២០១៣។ ប្រេវ៉ាឡង់ពលកម្មកុមារមានអត្រាខ្ពស់នៅឡើយ ប្រមាណ២% ប្រៀបធៀបនឹងចំណុចដៅ៨% ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

តារាង ២.៤- កុមារធ្វើការងារ និងចំណូលទទួលបាន (ចំណាត់ថ្នាក់ ការចំណាយ)

| ក្រុមចំណូល (ក្រុមចំណាយ)ក្នុងកម្រិត ២៥% | ទាបបំផុត ២៥% | ២៥-៥០% | ៥០-៧៥% | ខ្ពស់បំផុត ២៥% | សរុប | ប្រុស | ស្រី |
|---|---|---|---|---|---|---|---|
| កុមារធ្វើការងារ (%) ២០១១ (៦ -១៧ឆ្នាំ) | ២០,៧ | ១៦,៩ | ១១,៣ | ៦,៤ | ១៣,៦ | ១៣ | ១៤,១ |

ប្រភព: អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១១

**ប្រអប់២.៣- កំណត់ចំណាំ វិធីសាស្ត្រ**

ការអង្កេតរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិឆ្នាំ២០១២ និងការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅឆ្នាំ២០១៣ បានបង្ហាញលទ្ធផលទាំង២ផ្សេងគ្នាទៅលើស្ថានភាពបច្ចុប្បន្នរបស់កុមារ (ឧទាហរណ៍ កុមារពាក់ព័ន្ធនឹងការងារក្នុងរយៈពេល៧ថ្ងៃចុងក្រោយមុនការសម្ភាស) រីឯការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៣ (២០០៩, ២០១០ និង២០១១) បានប្រមូលទិន្នន័យដោយប្រើប្រាស់ "លក្ខខណ្ឌធម្មតា" (ឧទាហរណ៍ ពាក់ព័ន្ធនឹងការងាររយៈពេលវែង (សកម្មភាព ការងារជាគោលការណ៍ក្នុងរយៈពេល១២ខែចុងក្រោយ))។ លើសពីនេះទៀត មានចំនួនតួលេខខុសប្លែកពីគ្នាទៅលើការអង្កេតទាំងពីរនេះ។ ស្ថានភាពពលកម្មកុមារជាទូទៅលម្អៀងផ្តោតទៅលើការងារណាដែលរំខានដល់ការសិក្សារបស់កុមារ ប៉ះពាល់ដល់សុខភាព និងកុមារភាពរបស់ពួកគេ។ ការវាស់វែងស្ថានភាពបច្ចុប្បន្ននៃពលកម្មកុមារ ទំនង

មិនត្រឹមត្រូវពេញលេញនោះទេនៅក្នុងសង្គមដែលមានកសិកម្មតូចតាច និងមានសមាមាត្រយ៉ាងធំនៃការងារតាមរដូវ។ របាយការណ៍នេះ បានប្រើប្រាស់ប្រព័ន្ធទិន្នន័យរួមដើម្បីគោលបំណងផ្សេងៗពីគ្នា។

ការពិនិត្យមើលរបាយការណ៍ពលកម្មកុមារដោយបង្ខំនៅកម្ពុជា និងការអង្កេតពលកម្មកុមារនៅឆ្នាំ២០១២ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិខាងការងារនៅហ្សឺណែវ ខែវិច្ឆិកា ឆ្នាំ២០១៣ និងរបាយការណ៍អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ក្រសួងផែនការ និងរបាយការណ៍អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជា ក្រសួងផែនការ។

## កុមារអត់ចូលសាលានិងមិនធ្វើការងារ

កុមារមួយចំនួនអត់ចូលសាលានិងមិនបានធ្វើការងារក្នុងកម្លាំងពលកម្ម ឬនៅកន្លែងធ្វើការនោះទេ។ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា បានកំណត់ហេតុផលជាច្រើនសម្រាប់កុមារទាំងនោះ៖ កុមារចូលរួមក្នុងការងារគ្រួសារ(ជាពិសេសកុមារី) មិនមានសាលារៀននៅក្បែរលំនៅឋានពួកគេ កុមារមួយចំនួនគិតថាការសិក្សាមិនចាំបាច់ កុមារខ្លះទៀតរៀនធ្លាក់និងមិនចង់បន្តការសិក្សាតទៅទៀត។ល។ ក្នុងការវិភាគស៊ីជម្រៅ កុមារទាំងនោះបានបោះបង់ការសិក្សាដោយសារតម្រូវការជំនាញ កង្វះសម្ភារៈ ការអប់រំនិងការលើកទឹកចិត្តមានកម្រិត ព្រោះពួកគេមិនមានអ្វីដែលត្រូវធ្វើ។ តាមការប៉ាន់ប្រមាណអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រនៅកម្ពុជាឆ្នាំ២០១១ មានកុមារអត់ចូលសាលានិងមិនធ្វើការងារ ប្រមាណ៧%ក្នុងក្រុមកុមារអាយុ៦-១៧ឆ្នាំ គឺជាកុមារអត់ចូលសាលានិងមិនបានធ្វើការងារក្នុងកម្លាំងពលកម្ម កុមារា៧,៩% និងកុមារី៦,១%។ ជាតួលេខមានកុមារចំនួន១៨០ ០០០នាក់ដែលជាប្រភេទកុមារមិនបានចូលសាលានិងមិនបានធ្វើការងារក្នុងកម្លាំងពលកម្ម(ឆ្នាំ២០១១)។ តួលេខនេះអាចទាបជាងការប៉ាន់ស្មានដោយសារទិន្នន័យរបស់វិទ្យាស្ថានជាតិស្ថិតិ បង្ហាញអំពីការធ្លាក់ចុះច្រើននូវការចុះឈ្មោះចូលរៀនក្រោយបឋមសិក្សា ហើយសមាមាត្រពលកម្មកុមារកំពុងធ្លាក់ចុះយ៉ាងរហ័ស។ ស្ទើរតែ៣ដងនៃកុមារមិនបានចូលសាលានិងមិនបានធ្វើការងារ គឺជាក្រុមកុមារស្ថិតក្នុងគ្រួសារក្រីក្រក្នុងចំណោមប្រជាជនដែលមានកម្រិតចំណូលទាបបំផុតត្រឹម២៥% គឺមាន៩% ចំណែកកុមារក្នុងគ្រួសារចំណូលខ្ពស់(២៥% គឺមានតែ៣,៥%)។ មិនទាន់មានការទទួលស្គាល់ក្រុមកុមារប្រភេទនេះទេ ដូច្នេះក៏មិនទាន់មានគោលនយោបាយជាក់លាក់ដើម្បីជំរុញចុះឈ្មោះចូលរៀនរបស់កុមារទាំងនេះឱ្យមានការកើនឡើងដែរ។ ដូច្នេះ បើមានកុមារមិនបានចូលសាលានិងមិនបានធ្វើការងារ គឺជាការខាតបង់ធនធានមនុស្សនិងឱកាសជាច្រើន ដោយសារកុមារទាំងនេះទទួលការអប់រំតិចតួច និងមិនទទួលបានការលើកទឹកចិត្តពេញលេញ។ គោលនយោបាយតែមួយមិនអាចបំពេញតម្រូវការគ្រប់ៗគ្នាបានទេ។ កម្មវិធីសិក្សា បរិស្ថានតាមសាលារៀន និងការចំណាយនានា មិនបានទាក់ទាញដល់កុមារទាំងអស់នោះទេ ជាពិសេសសម្រាប់កុមារដែលស្ថិតក្នុងគ្រួសារក្រីក្រ ដូច្នេះត្រូវមានការវិភាគពីវិធីសាស្ត្រអូសទាញកុមារក្រីក្រឱ្យទទួលបានការសិក្សា។

## ១.២.៦- ច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងកុមារ

ផ្អែកលើគោលនយោបាយជាតិចំពោះកុមារ ព្រះរាជាណាចក្រកម្ពុជា បានកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងសិទ្ធិកុមារ ជាអាទិ៍៖

- ច្បាប់ស្តីពីការអប់រំ
- ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- ច្បាប់ស្តីពីការងារ
- ច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់
- អនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ

ការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធទាំងនេះ ទទួលបានលទ្ធផលវិជ្ជមានគួរឱ្យកត់សម្គាល់ តែនៅមានការខ្វះចន្លោះមួយចំនួនដោយមូលហេតុផ្សេងៗ ក្នុងនោះមានមូលហេតុផ្ទាល់គឺការខ្វះចន្លោះក្នុងខ្លឹមសារច្បាប់និងលិខិតបទដ្ឋានគតិយុត្តក្នុងការអនុវត្តដោយក្រសួង ស្ថាប័ន សមត្ថកិច្ចនិងអ្នកពាក់ព័ន្ធ និងបញ្ហាប្រឈមផ្សេងៗទៀតនៅក្នុងសង្គម រាប់ទាំងការយល់ដឹងរបស់ប្រជាជនយើងផង។ ជាមួយគ្នានេះ ស្ថានភាពមួយចំនួនរបស់កុមារមិនទាន់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តចែងនៅឡើយ ក្នុងស្ថានភាពការអភិវឌ្ឍរបស់កុមារសព្វថ្ងៃដូចជានីតិវិធីបណ្តឹងរបស់កុមារ កុមារប្រព្រឹត្តល្មើសនឹងច្បាប់ជាដើម។

### ១.២.៧- ឱកាសរបស់កុមារ

កម្ពុជា ជាប្រទេសដែលមានប្រជាជនវ័យក្មេងច្រើនជាងពាក់កណ្តាលនៃប្រជាជនសរុបមានអាយុក្រោម២៥ឆ្នាំដែលជាក្រុមអាយុពេញធ្វើការងារ។ ក្រុមប្រជាជនវ័យក្មេងបានបង្កើត "ផលលាភប្រជាសាស្ត្រ" ពីផលប្រយោជន៍សេដ្ឋកិច្ចនិងសង្គមដែលត្រូវចាប់ផ្តើមពីចរន្តលំហូរនៃការវិនិយោគទៅលើធនធានមនុស្ស សុខភាព និងការការពារសង្គម ហើយលើសពីនេះទៀត កម្លាំងពលកម្មលើវិស័យឧស្សាហកម្មត្រូវបានកំណត់ទៅលើវិស័យផ្សេងៗទៀត។

ទោះបីជាយើងមានឱកាសដោយសារប្រជាជនវ័យក្មេងដ៏ដោយ ដើម្បីសម្រេចបាននូវគោលដៅនេះលុះត្រាតែមាន៖

១- ការផ្តល់ឱកាសនិងធនធានមនុស្សគ្រប់គ្រាន់ និងប្រកបដោយចីរភាពសម្រាប់កុមារនៅពេលអនាគត។

២- កុមារត្រូវបានការការពារ និងផ្តល់នូវការយកចិត្តទុកដាក់គាំពារគ្រប់គ្រាន់ទាំងផ្លូវកាយនិងផ្លូវចិត្ត ដើម្បីឱ្យពួកគេមានសុខភាពល្អនិងរួចផុតពីភាពក្រីក្រ។

៣- កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីកាត់បន្ថយពលកម្មកុមារ ដើម្បីឱ្យកុមារទាំងនោះទទួលបានការសិក្សារៀនសូត្រ ការបណ្តុះបណ្តាលជំនាញ ហើយមានបរិស្ថានមួយប្រកបដោយសុវត្ថិភាពដែលគ្មានអំពើហិង្សានិងអំពើអបាយមុខផ្សេងៗ។

ការងារខាងលើនេះ អាចសម្រេចទៅបានលុះត្រាតែយន្តការជាតិត្រូវបានពង្រឹង មន្ត្រីមានសមត្ថភាពគ្រប់គ្រាន់ និងមានការផ្តល់ថវិកាគ្រប់គ្រាន់ ព្រមទាំងមានការចូលរួមកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិជាចាំបាច់។

## ១.៣- បញ្ហាអាទិភាព

ផ្អែកតាមការវិភាគស្ថានភាពកុមារគ្រប់ជ្រុងជ្រោយ ទាំងទិដ្ឋភាពច្បាប់ គោលនយោបាយ កម្មវិធីជាតិគ្រប់វិស័យពាក់ព័ន្ធទាំងអស់ រាជរដ្ឋាភិបាលកម្ពុជាដែលមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារជាសេនាធិការ បានរៀបចំផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ នេះឡើង ដើម្បីផ្តោតការយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សិទ្ធិកុមារនៅកម្ពុជា ដោយធានាឱ្យកុមារទាំងអស់នៅកម្ពុជា ទទួលបាននូវសិទ្ធិធំៗទាំងបួនពេញលេញរបស់ពួកគេ និងឱ្យធានាបាននូវឧត្តមប្រយោជន៍របស់កុមារកម្ពុជា ស្រមតាមច្បាប់រដ្ឋធម្មនុញ្ញ គោលនយោបាយជាតិ និងអនុសញ្ញាអន្តរជាតិ ពិសេសគឺអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ជាក្របខ័ណ្ឌការងារដ៏សំខាន់ និងជាផែនទីបង្ហាញផ្លូវសម្រាប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ ក្នុងការរៀបចំនិងអនុវត្តកម្មវិធីនានាឆ្លើយតបដល់តម្រូវការបន្ទាន់របស់កុមារ ដើម្បីរួមចំណែកសម្រេចឱ្យបានទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះដែរ ផែនការសកម្មភាពជាតិនេះបានវិភាគកំណត់រកនូវភាពខ្វះចន្លោះដែលមាននៅក្នុងយុទ្ធសាស្ត្រតាមវិស័យទាំងអស់ពាក់ព័ន្ធនឹងកុមារ ឆ្លុះបញ្ចាំងទៅនឹងសិទ្ធិមូលដ្ឋានរបស់កុមារនៅកម្ពុជា និងការប្តេជ្ញាចិត្តនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធ ទាំងក្របខ័ណ្ឌច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីជាតិនានា ដែលត្រូវការដោះស្រាយជាបន្ទាន់ដើម្បីកុមារ ទាំងការអនុវត្តសម្រាប់រយៈពេល៣ឆ្នាំខាងមុខ ក្នុងការឆ្លើយតបរបស់រាជរដ្ឋាភិបាល អង្គការជាតិនិងអន្តរជាតិពាក់ព័ន្ធ ដើម្បីអនុវត្តឱ្យសមស្របទៅតាមគោលដៅ និងយុទ្ធសាស្ត្ររបស់ក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិពាក់ព័ន្ធ។

ការសិក្សាអំពីស្ថានភាពកុមារនៅកម្ពុជា ដែលអធិប្បាយខាងលើបានបង្ហាញថា ទោះបីជាយើងបានខិតខំរួមគ្នារវាងក្រសួង ស្ថាប័ន អ្នកពាក់ព័ន្ធក៏ដោយ តាមរយៈផែនការសកម្មភាពជាតិរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រួមទាំងផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ក៏ស្ថានភាពកុមាររបស់យើងទាមទារឱ្យមានការខិតខំបន្តទៀត ដើម្បីឱ្យការបន្តវេនរបស់ពួកគេសម្រាប់អនាគតកម្ពុជាកាន់តែមានភាពធានាច្បាស់លាស់។

បញ្ហាកុមារនៅកម្ពុជាត្រូវបានភ្ជាប់ទៅនឹងកត្តាចម្បងពីរគឺ កត្តាគ្រួសារនិងកត្តាសង្គម។ ក្នុងស្ថានភាពដែលប្រជាជនយើងភាគច្រើនជាកសិករ កូននៅក្នុងគ្រួសារត្រូវចូលរួមកិច្ចការស្រែចម្ការជាមួយឪពុកម្តាយរបស់ពួកគេតាំងពីដើមរៀងមក ហើយក្នុងកាលៈទេសៈសព្វថ្ងៃ គ្រួសារមួយចំនួនបានផ្លាស់ទីលំនៅដោយមូលហេតុផ្សេងៗដែលនាំឱ្យប៉ះពាល់ដល់កុមារជាពិសេសការរៀនសូត្រ។ កត្តាសង្គមអវិជ្ជមានចំពោះកុមារមានដូចជា ការប្រើប្រាស់គ្រឿងញៀនដែលរីករាលដាលពីទីក្រុងទៅជនបទ។ នៅក្នុងផែនការនេះ បញ្ហាអាទិភាពត្រូវបានការប្រមូលផ្តុំជាពីរគឺ៖

- អាទិភាពដែលជាមូលដ្ឋានធានាការអភិវឌ្ឍអនាគតរបស់កុមារ : ការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- អាទិភាពជាដំណោះស្រាយបញ្ហាប្រឈមចំពោះមុខ : ការលុបបំបាត់រាល់ទម្រង់ផ្សេងៗដែលរំលោភបំពានមកលើកុមារ ការប្រើប្រាស់គ្រឿងញៀន ការលើកកម្ពស់សុខុមាលភាព និងការការពារកុមារ។



ឋា

# ២- យុទ្ធសាស្ត្រ

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ បានផ្តោតលើយុទ្ធសាស្ត្រជាក់លាក់ ដើម្បីបង្កើនល្បឿនឱ្យសម្រេចបាននូវការប្តេជ្ញាចិត្តដូចដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល។

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ បានកំណត់ក្របខ័ណ្ឌអនុវត្តន៍របស់រាជរដ្ឋាភិបាល ដោយផ្តោតលើកុមារគ្រប់វិស័យពាក់ព័ន្ធ។ ផែនការសកម្មភាពជាតិនេះ ត្រូវអនុវត្តដោយក្រសួងពាក់ព័ន្ធដោយផ្តោតលើការអភិវឌ្ឍ ការលើកកម្ពស់និងការពារសិទ្ធិកុមារ និងធានាឱ្យកុមារគ្រប់ៗរូបទទួលបានសិទ្ធិពេញលេញ និងមានប្រសិទ្ធភាព។ ផ្អែកលើបទពិសោធនានាដែលធ្លាប់បានឆ្លងកាត់មកហើយ យើងរំពឹងថា នៅប៉ុន្មានឆ្នាំខាងមុខនៃផែនការនេះ ការងារកុមារគ្រប់វិស័យពាក់ព័ន្ធនឹងទទួលបានលទ្ធផលល្អជាបន្តបន្ទាប់តាមរយៈការអនុវត្តយុទ្ធសាស្ត្រនីមួយៗ។ ផែនការសកម្មភាពជាតិនេះមានយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ ដូចខាងក្រោម៖

**យុទ្ធសាស្ត្រទី១- លើកកម្ពស់គុណភាពអប់រំនិងបណ្តុះបណ្តាលជំនាញ**

- ពង្រឹងគុណភាពសម្រាប់កុមារចាប់ពីអាយុ ៣ឆ្នាំ និងការអភិវឌ្ឍការសិក្សាអប់រំ ការគាំពារសង្គម
- កាត់បន្ថយចំនួនកុមារបោះបង់ការសិក្សានៅគ្រប់កម្រិតសិក្សា
- បង្កើនកាលានុវត្តភាពសម្រាប់ការបណ្តុះបណ្តាលជំនាញសម្រាប់កុមារ។

**យុទ្ធសាស្ត្រទី២- លើកកម្ពស់សុខុមាលភាពកុមារ**

- កែលម្អស្ថានភាពសេដ្ឋកិច្ចរបស់គ្រួសារក្រីក្រដើម្បីកុមារ
- លើកកម្ពស់ការថែទាំសុខភាព អាហារូបត្ថម្ភ និងការថែទាំកុមារ
- លើកកម្ពស់ការប្រើប្រាស់ទឹកស្អាតនិងអនាម័យដែលផ្តោតពិសេសលើកុមារ។

**យុទ្ធសាស្ត្រទី៣- ពង្រឹងកិច្ចគាំពារកុមារ និងការពារកុមារពីអំពើហិង្សានិងការងារដែលមានគ្រោះថ្នាក់**

- លុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារគ្រប់រូបភាពទាំងអស់
- កាត់បន្ថយ លុបបំបាត់អំពើហិង្សានិងការប្រើប្រាស់គ្រឿងញៀន
- កាត់បន្ថយ លុបបំបាត់អំពើជួញដូរកុមារនិងអំពើហិង្សាលើកុមារ
- ពង្រឹងបណ្តាញសហគមន៍សិទ្ធិកុមារ។

**យុទ្ធសាស្ត្រទី៤- ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តច្បាប់ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ**

- ពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍកុមារជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល សហគមន៍អាស៊ាន និងស្ថាប័នអង្គការសហប្រជាជាតិ
- ពិនិត្យឡើងវិញនិងអនុវត្តគោលនយោបាយនិងក្របខ័ណ្ឌច្បាប់ទាក់ទងនឹងបញ្ហានានារបស់កុមារ។

**យុទ្ធសាស្ត្រទី៥- ពង្រឹងយន្តការជាតិ សមត្ថភាព និងដំណើរការ**

- ពង្រឹងការសម្របសម្រួល ការត្រួតពិនិត្យ និងការសរសេររបាយការណ៍ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- ពង្រឹងការអនុវត្តយន្តការ និងការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងដៃគូពាក់ព័ន្ធអំពីគោលនយោបាយនិងច្បាប់នានាពាក់ព័ន្ធនឹងកុមារ។

# ៣- ផែនការសកម្មភាព

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារជាផ្នែកដ៏សំខាន់នៃផែនការជាតិទាំងមូល ត្រូវបានកសាងឡើងចេញពីការវិភាគស្ថានភាពកុមារ និងបញ្ហាអាទិភាពដើម្បីបង្ហាញអំពីការងារលម្អិតជាច្រើនដែលយើងត្រូវធ្វើឱ្យសម្រេចបានតាមរយៈយុទ្ធសាស្ត្រទាំង៥។ យន្តការរបស់ ក.ជ.ក. ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ មានតួនាទីយ៉ាងសំខាន់ដើម្បីធ្វើឱ្យផែនការសកម្មភាពជាតិនេះ ជាពិសេសយុទ្ធសាស្ត្រនិងសកម្មភាពនីមួយៗមានការសម្របសម្រួលអនុវត្តការតាមដានលើរាល់សកម្មភាពរបស់កុមារ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ និងការរៀបចំរបាយការណ៍ផ្សេងៗទទួលបានជោគជ័យ។

## ៣.១- បរិយាយសង្ខេបពីវិសាលភាពផែនការ

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ មានវិសាលភាពអនុវត្តទៅលើ៖

- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ដៃគូអភិវឌ្ឍ
- សង្គមស៊ីវិល
- អង្គការសាសនា
- កុមារ
- មាតាបិតា អាណាព្យាបាល និងប្រជាជនទូទៅ។

ក្នុងមុខងារនិងភារកិច្ចរបស់ខ្លួន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានខិតខំប្រឹងប្រែងសម្របសម្រួលជាពហុវិស័យ រវាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានានឹងបញ្ហាកុមារតាមរយៈយន្តការរបស់ខ្លួនទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ក្នុងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ នេះ ត្រូវបន្តការខិតខំបន្ថែមទៀតដើម្បីឱ្យលទ្ធផលរំពឹងទុកនិងសូចនាករសំខាន់ៗក្នុងសកម្មភាពនីមួយៗរបស់ផែនការដែលទទួលខុសត្រូវដោយក្រសួង ស្ថាប័ន ណាមួយអាចទទួលបានលទ្ធផលល្អ។

តារាងអនុវត្តការងារ(ម៉ាទ្រិក) ត្រូវបានរៀបចំផ្អែកលើយុទ្ធសាស្ត្រទាំង៥។ យុទ្ធសាស្ត្រនីមួយៗត្រូវបានបែងចែកជាចំណុចសំខាន់ៗដែលត្រូវអនុវត្តដោយសកម្មភាពច្រើន។

**យុទ្ធសាស្ត្រទី១- លើកកម្ពស់គុណភាពអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

+ ចំណុចទី១- ការអភិវឌ្ឍកុមារតូចកាន់តែប្រសើរ
+ ចំណុចទី២- ការសិក្សាអប់រំគ្រប់កម្រិតត្រូវបានពង្រឹង
+ ចំណុចទី៣- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់យុវកុមារ

**យុទ្ធសាស្ត្រទី២- លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ**

+ ចំណុចទី១- ស្ថានភាពសេដ្ឋកិច្ចគ្រួសារនិងសុខុមាលភាពសង្គមសម្រាប់កុមារត្រូវបានពង្រឹង
+ ចំណុចទី២- សុខភាពនិងអាហារូបត្ថម្ភត្រូវបានលើកកម្ពស់ឱ្យប្រសើរឡើង
+ ចំណុចទី៣- ជម្រកស្នាក់នៅនិងអនាម័យទឹកស្អាតត្រូវបានពង្រីកវិសាលភាពទូលាយ

**យុទ្ធសាស្ត្រទី៣- ពង្រឹងការការពារកុមារនិងការបង្ការទប់ស្កាត់**

+ ចំណុចទី១- ពលកម្មកុមារត្រូវបានកាត់បន្ថយ
+ ចំណុចទី២- អំពើហិង្សាលើកុមារនិងគ្រឿងញៀនត្រូវបានកាត់បន្ថយ
+ ចំណុចទី៣- អំពើជួញដូរកុមារត្រូវបានកាត់បន្ថយ
+ ចំណុចទី៤- បណ្តាញសហគមន៍សិទ្ធិកុមារត្រូវបានបង្កើត



៣

**យុទ្ធសាស្ត្រទី៤- ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតបទដ្ឋានគតិយុត្តនិងគោលនយោបាយ**

+ ចំណុចទី១- កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិត្រូវបានពង្រឹង
+ ចំណុចទី២- ក្របខ័ណ្ឌគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តត្រូវបានពង្រឹងការអនុវត្ត

**យុទ្ធសាស្ត្រទី៥- ពង្រឹងយន្តការជាតិនិងសមត្ថភាពបំពេញមុខងារឱ្យមានដំណើរការល្អ**

+ ចំណុចទី១- ពង្រឹងការសម្របសម្រួល ការត្រួតពិនិត្យ និងការសរសេររបាយការណ៍
+ ចំណុចទី២- ការបង្កើននិងអភិវឌ្ឍន៍សមត្ថភាព

## ៣.២- តារាងអនុវត្តការងារ

**យុទ្ធសាស្ត្រទី១- លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលជំនាញ**

គោលបំណង១)-អភិវឌ្ឍកុមារពីការចាប់ផ្តើមដំបូងនៃការអភិវឌ្ឍរបស់ពួកគេ(ចាប់ពីអាយុ៣ឆ្នាំ) ឱ្យកុមារទទួលបានការគាំទ្រយ៉ាងពេញលេញក្នុងការអភិវឌ្ឍ ការសិក្សា អប់រំ ការគាំពារសង្គម (ទាំងរាងកាយ ស្មារតី និងការសិក្សាអប់រំតាំងពីកុមារតូច) តាមរយៈការអនុវត្តកម្មវិធីចម្រុះ។ ២)-កាត់បន្ថយចំនួនកុមារបោះបង់ការសិក្សាគ្រប់កម្រិត (បឋមសិក្សា និងមធ្យមសិក្សា) និងធានាថាកុមារគ្រប់រូបបញ្ចប់ការសិក្សាមូលដ្ឋាន ៩ឆ្នាំ ស្របតាមគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨)។ ៣)-ពង្រីកវិសាលភាព និងផ្តល់ឱកាសការបណ្តុះបណ្តាលជំនាញពេញលេញ ដល់យុវកុមារដែលជាក្រុមកុមារងាយរងគ្រោះ ដើម្បីពួកគេមានជម្រើសសម្រាប់ឱកាសការងារ និងការប្រកបមុខរបរចិញ្ចឹមជីវិតឱ្យបានប្រសើរឡើង។

**១.១- ចំណុចទី១- ការអភិវឌ្ឍកុមារតូចកាន់តែប្រសើរឡើង**

**លទ្ធផលៈ** អត្រា៥៥% នៃកុមារដែលមានក្រុមអាយុពី៣-៥ឆ្នាំ មានការកើនឡើងក្នុងការចុះឈ្មោះចូលរៀនមត្តេយ្យសិក្សាដើម្បីការអភិវឌ្ឍកុមារតូច។ ទិន្នផលនេះផ្តោតលើការអភិវឌ្ឍកុមារតូច ដើម្បីផ្តល់ឱកាសការសិក្សាអប់រំចាប់តាំងពីមត្តេយ្យសិក្សា និងទទួលបានការបណ្តុះបណ្តាលចាប់តាំងពីកុមារភាព ស្តីពីចំណេះដឹងសង្គម ភាសា ស្មារតី។ល។ ដោយធានាឱ្យសម្រេចបាននូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅឆ្នាំ២០១៨។

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ១.១.១- កែសម្រួលកម្មវិធីសិក្សានៅសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ កម្មវិធីតាមផ្ទះ និងជំរុញការផ្សព្វផ្សាយ ការចុះឈ្មោះចូលរៀនសាលាមត្តេយ្យសហគមន៍ឱ្យបានទូលំទូលាយ | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.១.២- ពិនិត្យនិងរៀបចំឱ្យមានកម្មវិធីបង្រៀនពហុភាសាចាប់ពីថ្នាក់មត្តេយ្យសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.១.៣- រៀបចំឱ្យមានល្បែងកម្សាន្តបែបកុមារមេត្រី ដោយមានមេរៀន សម្ភារៈសិក្សា បង្កើនសម្ភារៈលេងកម្សាន្ត និងកែលម្អបរិស្ថានសាលាឱ្យមានផាសុកភាពនិងមានសុវត្ថិភាព | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.១.៤- បង្កើនចំនួនគ្រូ ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ និងរៀបចំគោលការណ៍ពង្រីកក្របខ័ណ្ឌនៃការបណ្តុះបណ្តាលគ្រូបង្រៀនសាលាមត្តេយ្យ និងរៀបចំគោលការណ៍សម្រាប់ឪពុកម្តាយ អាណាព្យាបាល ស្តីពីអាហារូបត្ថម្ភ ការគាំពារកុមារ និងការប្រើប្រាស់សេវាសុខភាព | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.១.៥- រៀបចំនិងណែនាំគោលការណ៍ស្តីពីប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃ ដោយផ្អែកលើលទ្ធផលការអប់រំកុមារតូច | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |

| | |
|---|---|
| ១.១.៦- រៀបចំសេចក្តីណែនាំសម្រាប់ការចូលរួមពីវិស័យឯកជនក្នុងសកម្មភាពអប់រំកុមារតូច | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.១.៧- កែសម្រួលតួនាទីរបស់នាយកដ្ឋានអប់រំកុមារតូចដើម្បីឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងមហាផ្ទៃ |
| ១.១.៨- រៀបចំគោលការណ៍អភិបាលកិច្ចល្អសម្រាប់មត្តេយ្យសិក្សា និងរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសាលាតាមសហគមន៍ សាលាមត្តេយ្យ និងកម្មវិធីសិក្សាតាមផ្ទះ | ក្រសួងអប់រំ យុវជន និងកីឡា |

**១.២- ចំណុចទី២- ការសិក្សាអប់រំគ្រប់កម្រិតត្រូវបានពង្រឹង**

**លទ្ធផល:** ជានាឱ្យបានសម្រេចគោលដៅអត្រា ១០០ភាគរយ នៃកុមារគ្រប់អាយុចុះឈ្មោះចូលរៀននៅថ្នាក់បឋមសិក្សា និង៨៧% មធ្យមសិក្សា ហើយធានាថាអត្រាបោះបង់ការសិក្សាមានការថយចុះ (គ្មានកុមារបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាអត្រាបោះបង់ឱ្យមានការថយចុះនៅត្រឹមតែ៣%)នៅឆ្នាំ២០១៨។ ទិន្នផលនេះផ្តោតលើការសិក្សាអប់រំសម្រាប់កុមារគ្រប់កម្រិត ពិសេសថ្នាក់បឋមសិក្សារហូតដល់ថ្នាក់មធ្យមសិក្សា ដោយផ្តោតការយកចិត្តទុកដាក់លើកុមារងាយរងគ្រោះ និងកុមារមកពីគ្រួសារក្រីក្រ

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ១.២.១- ចាត់វិធានការនិងបង្កើនអន្តរាគមន៍ដល់ការអប់រំកុមារគ្រប់ៗរូប ឱ្យបានបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (យ៉ាងតិចត្រឹមថ្នាក់ទី៩) ដោយផ្តល់អាទិភាពដល់កុមារក្រីក្រ ជាពិសេសកុមារពិការ កុមារជនជាតិដើមភាគតិច និងកុមារបម្លាស់ទីនិងកុមារក្នុងពន្ធនាគារ។ល។(ក្រុមកុមារដែលបាត់បង់ឱកាស) | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងមហាផ្ទៃ |
| ១.២.២- ពង្រីកហេដ្ឋារចនាសម្ព័ន្ធអប់រំនៅគ្រប់កម្រិត ដូចជាកម្រិតទារកដ្ឋាន មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា និងកម្រិត ផ្សេងៗទៀត។ ត្រូវបង្កើនចំនួនបន្ទប់រៀន និងរៀបចំគ្រូបង្រៀនតាមតម្រូវការ និងរៀបចំឱ្យមានទឹកស្អាត និង បង្គន់អនាម័យតាមសាលារៀន។ ក្នុងករណីខ្លះ អាចរៀបចំការដឹកជញ្ជូនកុមារទៅសាលារៀនចំពោះសាលារៀន ដែលនៅឆ្ងាយពីភូមិ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១.២.៣- បង្កើនការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ ចំពោះក្រុមកុមារដែលបាត់បង់ឱកាស នៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា |
| ១.២.៤- បង្កើតនិងពង្រឹងគណៈកម្មការទ្រទ្រង់សាលា ដើម្បីតាមដានវឌ្ឍនភាពនៃការអប់រំ។ នេះគឺជាការពិនិត្យតាមដានវាយតម្លៃនិងដោះស្រាយបញ្ហាដំបូងទាក់ទងនឹងការមិនចូលរៀន ឬការបោះបង់ការសិក្សា និងបញ្ហាពាក់ពន្ធ័របស់កុមារ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | |
|---|---|
| ១.២.៥- កែសម្រួលកម្មវិធីសិក្សាទាក់ទងទៅនឹងទីផ្សារការងារ និងការផ្សារភ្ជាប់ការអប់រំតាមសាលាជាមួយការបណ្តុះបណ្តាលបច្ចេកទេស | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងមហាផ្ទៃ |
| ១.២.៦- រៀបចំកម្មវិធីអប់រំពិសេសសម្រាប់កុមារពិការឱ្យទទួលបានសេវាអប់រំ ដោយរៀបចំទីកន្លែងដូចជាជម្រាលបន្ទប់រៀន បន្ទប់ទឹកសម្រាប់សម្រួលកុមារពិការ ព្រមទាំងបង្កើនសកម្មភាព "មិត្តអប់រំមិត្ត" នៅតាមសាលារៀន | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១.២.៧- ដាក់បញ្ចូលពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ និងពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ទៅក្នុងកម្មវិធីសិក្សានៃសាលាចំណេះទូទៅ សាកលវិទ្យាល័យ សាលាបច្ចេកទេសយោធា សាលានាយទាហាន សាលានគរបាល សាលាយុត្តិធម៌។ល។ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ១.២.៨- បន្តពង្រឹង ចាត់វិធានការ គាំទ្រដល់សិស្សបោះបង់ការសិក្សា ដើម្បីឱ្យមានការរៀនសូត្រ ឬការបំប៉នឡើងវិញក្នុងគោលបំណងសមាហរណកម្មបន្តក្នុងសាលាសាធារណៈឬតម្រង់ទិសតាមសាលាវិជ្ជាជីវៈ | ក្រសួងក្រសួងអប់រំ យុវជន និងកីឡា |
| ១.២.៩- សិក្សាពីលទ្ធភាពក្នុងការបញ្ចូលមេរៀនអំពីការហែលទឹកទៅក្នុងកម្មវិធីសិក្សានៅតំបន់ តាមរយៈការសហការជាមួយវិស័យឯកជន ក្នុងការលើកកម្ពស់វិស័យកីឡា និងបង្រៀនកុមារឱ្យចេះហែលទឹក ដែលជាជំនាញជួយឱ្យកុមាររួចផុតពីការលង់ទឹក | ក្រសួងអប់រំ យុវជន និងកីឡា<br>គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| **១.៣- ចំណុចទី៣- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់យុវកុមារ**<br>**លទ្ធផលៈ** បង្កើនមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសម្រាប់យុវកុមារ (អាយុ១៥ ទៅក្រោម ១៨ឆ្នាំ) ឱ្យបានកើនឡើងទូទាំងប្រទេស យ៉ាងហោចណាស់ឱ្យមានមណ្ឌល១ ក្នុងមួយខេត្តនៅឆ្នាំ២០១៨។ លទ្ធផលនេះផ្តោតលើក្រុមកុមារដែលបាត់បង់ឱកាសមិនមានលទ្ធភាពបន្តការសិក្សាក្នុងប្រព័ន្ធ ឱ្យមានជម្រើសសមរម្យទទួលបានការបណ្តុះបណ្តាលជំនាញឬជំនាញបំណិនជីវិតសម្រាប់អនាគត និងឱ្យមានឱកាសស្វែងរកការងារសមរម្យនៅពេលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ១.៣.១- បង្កើតកម្មវិធីបណ្តុះបណ្តាលឱ្យមានស្តង់ដា ដោយផ្តោតលើគុណភាព និងរយៈពេលសិក្សាការបណ្តុះបណ្តាល សម្ភារៈសិក្សា និងទីផ្សារការងារ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១.៣.២- បង្កើនចំនួនសិស្ស សិក្ខាកាមឱ្យចូលរៀនវគ្គបណ្តុះបណ្តាល ទៅតាមជំនាញដែលមានតម្រូវការទីផ្សារការងារខ្ពស់ ដូចជាជំនាញផ្នែកវិស្វកម្ម អេឡិចត្រូនិក អគ្គិសនី គ្រឿងម៉ាស៊ីន កសិកម្ម និងសំណង់ រួមទាំងជំនាញផ្សេងៗទៀត | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |



៦

| | |
|---|---|
| ១.៣.៣- រៀបចំផែនការនិងគម្រោងស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់យុវកុមារដែលរស់នៅក្នុងមណ្ឌលឱ្យបានសមរម្យ មុនធ្វើសមាហរណកម្មទៅក្នុងសហគមន៍ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ១.៣.៤- ផ្តួចផ្តើមរៀបចំកិច្ចពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជន ដើម្បីពិនិត្យមុខវិជ្ជាក្នុងការតម្រង់ទិសដល់អ្នកសិក្សា ស្តីពីវិធីការងារតាមតម្រូវការទីផ្សារការងារ ក្រៅពីមុខវិជ្ជាធ្វើសក់ កែសម្ផស្ស ធ្វើម្ហូប ជាដើម សំដៅមុខជំនាញសំខាន់ៗដូចជា វិស្វកម្ម បដិសណ្ឋារកិច្ច អ្នកធ្វើការសុខភាពសហគមន៍។ល។ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា |
| ១.៣.៥- ផ្តួចផ្តើមរៀបចំសម្របសម្រួលនិងពិភាក្សាជាមួយវិស័យឯកជន និងស្វែងរកដៃគូអភិវឌ្ឍឬធនាគារ ដើម្បីរៀបចំបទដ្ឋាន ការកំណត់តម្លៃសម្រាប់វគ្គបណ្តុះបណ្តាលជំនាញឱ្យបានសមរម្យ។ លើសពីនេះ ជួយរកអាហារូបករណ៍សម្រាប់សិស្សឬក្រុមកុមារដែលបាត់បង់ឱកាស | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា |
| ១.៣.៦- រៀបចំសម្របសម្រួលបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតាមតំបន់ឬខេត្តដែលមានសក្តានុពលដល់ក្រុមកុមារដែលបាត់បង់ឱកាសមកពីគ្រួសារក្រីក្រ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងកិច្ចការនារី<br>ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១.៣.៧- រៀបចំវេទិកាជាតិ ដោយមានការចូលរួមពីវិស័យឯកជន ដើម្បីកំណត់មុខជំនាញសំខាន់ៗដែលត្រូវការសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្សតាមជំនាញទៅតាមតម្រូវការទីផ្សារការងារ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងផែនការ |
| ១.៣.៨- បង្កើតឱ្យមានមូលនិធិសម្រាប់សិស្សដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ ដើម្បីមានកញ្ចប់ថវិកាធ្វើដើមទុនវិនិយោគសម្រាប់មុខរបរ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងអប់រំ យុវជន និងកីឡា<br>ធនាគារជាតិនៃកម្ពុជា |

**យុទ្ធសាស្ត្រទី២- លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ**

គោលបំណង ១)-ធ្វើឱ្យប្រសើរឡើងនូវជីវភាពសេដ្ឋកិច្ចគ្រួសារ និងកុមារក្រីក្រតាមរយៈការផ្តល់ឱ្យពួកគេទទួលបានបណ្ណក្រីក្រ។ លើសពីនេះទៅទៀត គោលបំណងនេះនឹងដោះស្រាយរាល់បញ្ហានានារាប់បញ្ចូលទាំងកុមារដែលប្រឈមនឹងការមិនយកចិត្តទុកដាក់ពីសង្គម តាមរយៈកម្មវិធីសមាហរណកម្មពហុវិស័យរួមទាំងកម្មវិធីអភិវឌ្ឍន៍សមាហរណកម្ម ស្តារនីតិសម្បទា និងការការពារកុមារដែលរស់នៅដាច់ដោយឡែកពីគ្រួសារ។ ២)-ផ្តល់ការថែទាំសុខភាពៈ អាហារូបត្ថម្ភកុមារ ផ្តល់វ៉ាក់សាំងបង្ការដល់កុមារ

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ស្របតាមផែនការនិងគោលនយោបាយសុខភាព និងសូចនាករគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨។ ៣)-ធ្វើឱ្យប្រសើរឡើងនូវអនាម័យទឹកស្អាត ដល់គ្រួសារ សហគមន៍ទាំងអស់ ជាពិសេស ផ្តោតការយកចិត្តទុកដាក់លើកុមារ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់កុមារ ទាំងនៅប្រជុំជន និងតាមជនបទ។ | |
| **២.១- ចំណុចទី១- ស្ថានភាពសេដ្ឋកិច្ចគ្រួសារនិងសុខុមាលសង្គមសម្រាប់កុមារត្រូវបានពង្រឹង**<br>**លទ្ធផល**: យ៉ាងហោចណាស់អត្រា ១ ភាគរយ នៃកុមារក្រីក្រត្រូវបានកាត់បន្ថយជារៀងរាល់ឆ្នាំ ដើម្បីធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចគ្រួសារនិងកុមារឱ្យកាន់តែប្រសើរ និងការលើកកម្ពស់កិច្ចគាំពារសង្គមឱ្យសម្រេចបាននៅឆ្នាំ២០១៨។ លទ្ធផលនេះ គឺជានាដល់ការពង្រឹងសេដ្ឋកិច្ចគ្រួសារ ព្រោះថាបញ្ហាដែលកុមារបាននិងកំពុងប្រឈមគឺបណ្តាលមកពីភាពក្រីក្រ។ ការកាត់បន្ថយភាពក្រីក្រ ១ ភាគរយ នឹងចូលរួមជួយកាត់បន្ថយភាពក្រីក្រកុមារ។ ការកាត់បន្ថយភាពក្រីក្រធ្វើឱ្យសុខុមាលភាព និងការដាក់បញ្ចូលរបស់កុមារ ទៅក្នុងការអភិវឌ្ឍកាន់តែមានភាពប្រសើរឡើង។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ២.១.១- រៀបចំការសិក្សា ប្រមូលព័ត៌មាន និងបង្កើតកម្មវិធីសម្រាប់ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចគ្រួសារ រួមទាំងការលើកកម្ពស់សមភាពយេនឌ័រ | ក្រសួងផែនការ |
| ២.១.២- ចាត់វិធានការនានា នាំយកកុមារឱ្យមានការថែទាំពីគ្រួសារ (កុមារអនាថា កុមាររស់នៅក្នុងមណ្ឌល និងតាមវត្តអារាម)តាមរយៈការផ្តល់សេវាកម្មពេញលេញសម្រាប់ការស្តារនីតិសម្បទានិងសមាហរណកម្ម។ កុមារទាំងនោះត្រូវធ្វើសមាហរណកម្មទៅគ្រួសារផ្ទាល់ឬឪពុកម្តាយចិញ្ចឹមឬគ្រួសារផ្សេងទៀត | ក្រសួងផែនការ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ២.១.៣- ពង្រឹងការធ្វើអន្តរាគមន៍របស់នគរបាលយុត្តិធម៌និងអាជ្ញាធរដែនដី ការពារ ទប់ស្កាត់ កុមារពីការគំរាមកំហែងគ្រប់រូបភាព | ក្រសួងមហាផ្ទៃ<br>ក្រសួងទេសចរណ៍<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ២.១.៤- បន្តការរៀបចំនិងអនុវត្តការផ្តល់បណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី និងផ្តល់ដីសម្បទានសង្គមកិច្ចដើម្បីបង្កើនលទ្ធភាពសេដ្ឋកិច្ចគ្រួសារ ។ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ២.១.៥- បន្តការផ្សព្វផ្សាយពីភាពគ្រោះថ្នាក់ដោយសារគ្រាប់មីនដល់កុមារ ពិសេសក្នុងតំបន់ដែលមានមីន និងបន្តការបោសសម្អាតមីនឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ | មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា |
| ២.១.៦- ផ្សព្វផ្សាយ និងចាត់វិធានការបង្ការទប់ស្កាត់ស្តីពីផលប៉ះពាល់ដោយគ្រោះមហន្តរាយធម្មជាតិនិងបម្រែបម្រួលអាកាសធាតុ(ខ្យល់ព្យុះ រន្ទះ ទឹកជំនន់ រាំងស្ងួត។ល។) | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |



ឥ

| | |
|---|---|
| ២.១.៧- បន្តរៀបចំវេទិកានៅតាមសហគមន៍ ដើម្បីឱ្យមាតាបិតាអាណាព្យាបាលកុមារ អាចលើកកម្ពស់ស្ថានភាពអភិវឌ្ឍកុមារ និងសុវត្ថិភាពសុខុមាលភាពរបស់កុមារ | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ២.១.៨- រៀបចំការវាយតម្លៃសមត្ថភាពស្ដីពីការថែទាំកុមារនៅតាមមណ្ឌលទាំងអស់ ការដោះស្រាយកុមារងាយរងគ្រោះ និងកុមារពិការ កុមាររងគ្រោះ និងក្រុមកុមារផ្សេងៗទៀត និងរៀបចំសៀវភៅការបណ្ដុះបណ្ដាល និងការវាយតម្លៃ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងធម្មការនិងសាសនា |
| ២.១.៩- ធ្វើឱ្យប្រសើរឡើងប្រព័ន្ធទិន្នន័យស្ដីពីកុមារកំព្រានិងកុមារងាយរងគ្រោះ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **២.២- ចំណុចទី២- សុខភាពនិងអាហារូបត្ថម្ភត្រូវបានលើកកម្ពស់ឱ្យប្រសើរឡើង**<br>**លទ្ធផលៈ** បង្កើនអាហារូបត្ថម្ភដល់កុមារ (លើសពី ៩០ ភាគរយ កុមារទទួលបានការថែទាំ) ពិសេសកុមារក្រីក្រ។ ធានាថា កុមារគ្រប់ៗរូបតាំងពីកំណើតរហូតដល់ពេញវ័យនឹងត្រូវទទួលបានការថែទាំសុខភាពមូលដ្ឋានយ៉ាងល្អប្រសើរ រួមទាំងការបំបៅកូនដោយទឹកដោះម្ដាយ ការចាក់ថ្នាំបង្ការ ការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ និងការប្រឹក្សាយោបល់ពីឪពុកម្ដាយអំពីផែនការគ្រួសារ។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ២.២.១- បន្តការអនុវត្តកម្មវិធីស្ដីពីការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារទៅតាមស្តង់ដាដែលបានកំណត់ | ក្រសួងផែនការ |
| ២.២.២- បង្កើនការផ្តល់បណ្ណសមធម៌ដល់ប្រជាជនក្រីក្រ (ដែលមានប្រហែល ២០ ភាគរយទូទាំងប្រទេស) ចំពោះគ្រួសារក្រីក្រដែលស្ថិតក្នុងចំណាត់ថ្នាក់មានចំណូលទាប ៣០-៤០% សម្រាប់គ្រួសារក្រីក្រ ឱ្យទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ | ក្រសួងផែនការ |
| ២.២.៣- ពង្រីកអន្តរាគមន៍អាហារូបត្ថម្ភបន្ថែមទៀតដល់កុមារឱ្យបានច្រើនបំផុតចំពោះកុមារដែលមានអាយុពី (០ឆ្នាំ ដល់ ៥ឆ្នាំ) | ក្រសួងសុខាភិបាល |
| ២.២.៤- ធ្វើឱ្យប្រសើរឡើងការពន្យារកំណើតដើម្បីជួយរក្សាស្ថានភាពសេដ្ឋកិច្ចគ្រួសារទទួលបានចំណូលខ្ពស់ជាងមុន ព្រមទាំងម្ដាយមានសុខភាពល្អ ដែលនាំឱ្យមានការថែទាំកុមារបានប្រសើរជាងមុន | ក្រសួងសុខាភិបាល |
| ២.២.៥- បន្តពង្រឹងការចុះបញ្ជីសំបុត្រកំណើតដល់កុមារដោយមិនបង់ប្រាក់ទូទាំងប្រទេស | ក្រសួងមហាផ្ទៃ |

| | |
|---|---|
| ២.២.៦- ពង្រឹងប្រព័ន្ធទិន្នន័យ និងធ្វើការវិភាគទិន្នន័យពីប្រព័ន្ធព័ត៌មានគ្រប់គ្រងវិស័យសុខាភិបាល ដើម្បីធ្វើប្រព័ន្ធត្រួតពិនិត្យតាមដានឱ្យកាន់តែមានភាពប្រសើរឡើងស្តីពីការអភិវឌ្ឍកុមារ | ក្រសួងផែនការ<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ២.២.៧- លើកកម្ពស់និងជំរុញការផ្តល់សេវាមុននិងក្រោយការសម្រាលនៅមូលដ្ឋានសុខាភិបាល | ក្រសួងសុខាភិបាល |
| **២.៣- ចំណុចទី៣- ជម្រកស្នាក់នៅនិងអនាម័យទឹកស្អាតត្រូវបានពង្រីកវិសាលភាពទូលាយ**<br>**លទ្ធផល:** អត្រា ៦៧%នៃប្រជាជននៅតាមជនបទ និង៨៥%នៃប្រជាជននៅទីប្រជុំជនទទួលបានទឹកស្អាត និងប្រជាជន៦០%នៅទីជនបទ និង៨០% នៃប្រជាជននៅប្រជុំជនទទួលបាននូវសុខភាពអនាម័យ នៅឆ្នាំ២០១៨។ លទ្ធផលនេះ គឺផ្តោតទៅលើតម្រូវការចាំបាច់មូលដ្ឋានរបស់កុមារ ដើម្បីអភិវឌ្ឍពួកគេទាំងនៅជនបទ និងនៅទីប្រជុំជន។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ២.៣.១- រៀបចំការសិក្សាស្រាវជ្រាវស្តីពីទឹកនិងអនាម័យ ដើម្បីកំណត់បញ្ហាពិតប្រាកដទាក់ទងនឹងការប្រើប្រាស់ទឹកនិងការប្រតិបត្តិអនាម័យ ជាពិសេសនៅតាមជនបទ និងធ្វើការបណ្តុះបណ្តាលផ្សព្វផ្សាយនិងជំរុញការលើកកម្ពស់អនាម័យនិងការប្រើប្រាស់ទឹកនៅជនបទ | ក្រសួងផែនការ<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ២.៣.២- ដាក់បញ្ចូលការងារទឹកស្អាត អនាម័យ និងការផ្គត់ផ្គង់សម្ភារៈអនាម័យ ជាពិសេសតំបន់ជនបទ ទៅក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ២.៣.៣- លើកកម្ពស់ការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យតាមសាលារៀនគ្រប់កម្រិត ដើម្បីសុខភាពនិងសេចក្តីថ្លៃថ្នូររបស់កុមារ ជាពិសេសកុមារី | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងអភិវឌ្ឍន៍ជនបទ |
| ២.៣.៤- រៀបចំការសិក្សាស្រាវជ្រាវស្តីពីខ្វះផ្ទះ ដើម្បីកំណត់បញ្ហាពិតប្រាកដទាក់ទងនឹងជម្រករស់នៅដែលប៉ះពាល់ដល់កុមារនិងសុខភាព | ក្រសួងផែនការ<br>ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ក្រសួងអភិវឌ្ឍន៍ជនបទ |
| ២.៣.៥- រៀបចំគោលការណ៍និងគាំទ្រដល់គ្រួសារក្រីក្រដែលគ្មានផ្ទះ ជម្រករស់នៅសមរម្យតាមលក្ខខណ្ឌសុវត្ថិភាពសង្គម | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣- ពង្រឹងការការពារកុមារនិងការបង្ការទប់ស្កាត់**<br>**គោលបំណង: ១)-សម្រេចឱ្យបានគោលដៅលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។ ២)-កៀរគរអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីគាំទ្រយុទ្ធសាស្ត្រនេះក្នុងការកាត់បន្ថយរាល់ការកេងប្រវ័ញ្ចនិងអំពើហិង្សាលើកុមារគ្រប់រូបភាព។ ៣)-លុបបំបាត់អំពើជួញដូរកុមារ និង ៤)-លើកកម្ពស់បណ្ដាញសហគមន៍ដើម្បីសិទ្ធិកុមារ។** | |
| **៣.១- ចំណុចទី១- ពលកម្មកុមារត្រូវបានកាត់បន្ថយ**<br>**លទ្ធផល:** កាត់បន្ថយសមាមាត្រពលកម្មកុមារទូទាំងប្រទេសឱ្យនៅត្រឹមតែ៨% និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារឱ្យអស់នៅឆ្នាំ២០១៨។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ៣.១.១- បង្កើនការយល់ដឹងឱ្យកាន់តែប្រសើរឡើងតាមរយៈវេទិកាពិភាក្សារវាងក្រសួង ស្ថាប័នសំខាន់ៗពាក់ព័ន្ធស្តីពីពលកម្មកុមារ និងអនុវត្តកម្មវិធីកាត់បន្ថយលុបបំបាត់ពលកម្មកុមារគ្រប់វិស័យ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.១.២- សិក្សាស្រាវជ្រាវបន្ថែមអំពីប្រភេទការងារដែលមានស្រាប់ និងកំណត់ទំហំស្ថានភាពពលកម្មកុមារ និងកំណត់ចំនួនពលកម្មកុមារនៅកម្ពុជាឱ្យបានជាក់លាក់ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.១.៣- អនុវត្តកម្មវិធីការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងការលុបបំបាត់ពលកម្មកុមារ និងពង្រឹងការសិក្សារបស់កុមារ | ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងអប់រំ យុវជន និងកីឡា |
| ៣.១.៤- បន្តការអនុវត្តច្បាប់ស្តីពីការងារ ការផ្សព្វផ្សាយ ការពិនិត្យ និងការរៀបចំផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យនិងអធិការកិច្ចពលកម្មកុមារ នៅក្នុងវិស័យរៀបរយនិងមិនរៀបរយ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.១.៥- បង្កើតកម្មវិធីអប់រំដល់ឪពុកម្តាយឬអាណាព្យាបាលស្តីពីផលប៉ះពាល់មិនល្អ ផលវិបាកនានានៃពលកម្មកុមារ និងតម្លៃនៃការសិក្សាអប់រំរបស់កុមារនាពេលអនាគត | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | |
|---|---|
| ៣.១.៦- ប្រើប្រាស់ប្រព័ន្ធទិន្នន័យឃុំ សង្កាត់ជាសាធារណៈដើម្បីទទួលបានទិន្នន័យកាន់តែប្រសើរទាក់ទងនឹងស្ថានភាពកុមារ | ក្រសួងអភិវឌ្ឍន៍ជនបទ<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៣.១.៧- ផ្តល់វគ្គបណ្តុះបណ្តាលជំនាញសម្រាប់កុមារដែលបោះបង់ការសិក្សា (អាយុ១៥ ដល់ក្រោម១៨) ហើយពួកគេចង់ទទួលបានជំនាញបច្ចេកទេសសម្រាប់មុខរបរចិញ្ចឹមជីវិត | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.១.៨- បង្កើតក្រមសីលធម៌សម្រាប់ភ្នាក់ងារជ្រើសរើសពលករ ពិសេសផ្តោតលើកុមារ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **៣.២- ចំណុចទី២- អំពើហិង្សាលើកុមារនិងគ្រឿងញៀនត្រូវបានកាត់បន្ថយ**<br>**លទ្ធផល:** ធានានូវការអនុម័តគោលនយោបាយ ក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនានា ដើម្បីការពារនិងបង្ការទប់ស្កាត់អំពើហិង្សា និងការរើសអើងគ្រប់រូបភាព។ ការយកចិត្តទុកដាក់ជាពិសេសចំពោះកុមារបាត់បង់ឱកាស កុមារនៅក្នុងវិស័យ នេះមិនអាចកំណត់គោលដៅជាចំនួនតួលេខជាក់លាក់បាន ពីព្រោះលក្ខណៈប្រធានបទមានភាពស្មុគស្មាញ ហើយការវាស់វែងលទ្ធផលមិនអាចមានភាពជាក់ស្តែងបាននៅទូទាំងប្រទេស | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ៣.២.១- បង្កើតផែនការសកម្មភាពពហុវិស័យជាក់លាក់ដែលមានការប៉ាន់ប្រមាណតម្លៃ ក្នុងការឆ្លើយតបការប្រយុទ្ធប្រឆាំងអំពើហិង្សាលើកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងកិច្ចការនារី |
| ៣.២.២- រៀបចំក្របខ័ណ្ឌការងារត្រួតពិនិត្យនិងវាយតម្លៃ និងការប្រយុទ្ធប្រឆាំងអំពើហិង្សាលើកុមារ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៣.២.៣- លើកកម្ពស់តម្លៃគ្រួសារ បំបាត់អំពើហិង្សាលើកុមារ តាមរយៈការចាប់ផ្តើមការងារសង្គមតាមសហគមន៍ និងលើកកម្ពស់តម្លៃព្រះពុទ្ធសាសនា ដើម្បីពង្រឹងការគាំពារកុមារ។ សម្រាប់ជំហានដ៏សំខាន់នេះ ត្រូវដាក់បញ្ចូលបញ្ហាកុមារទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់។ ផែនការឃុំ សង្កាត់ត្រូវរួមបញ្ចូលបញ្ហានានារបស់កុមារ រួមទាំងក្រុមកុមារដែលបាត់បង់ឱកាស | ក្រសួងអប់រំ យុវជន និងកីឡា<br>ក្រសួងធម្មការនិងសាសនា<br>ក្រសួងកិច្ចការនារី<br>ក្រសួងមហាផ្ទៃ |
| ៣.២.៤- ត្រួតពិនិត្យតាមដាន ដើម្បីទទួលបាននូវអាហារូបត្ថម្ភ សេវាសុខភាព និងការអប់រំរបស់កុមារ ការការពារ និងការថែទាំកុមារតាមឪពុកម្តាយនៅក្នុងពន្ធនាគារ | ក្រសួងសុខាភិបាល<br>ក្រសួងអប់រំ យុវជន និងកីឡា |

| | |
|---|---|
| ៣.២.៥- ផ្សព្វផ្សាយនិងបង្កើនការអនុវត្តច្បាប់ស្តីពីគ្រឿងញៀនឱ្យកាន់តែប្រសើរដល់សហគមន៍ សាលារៀន វត្តអារាម តាមរយៈបណ្តាញផ្សព្វផ្សាយនានា | ក្រសួងមហាផ្ទៃ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.២.៦- រៀបចំច្បាប់ បទប្បញ្ញត្តិស្តីពីការទិញគ្រឿងស្រវឹង ផលិតផលថ្នាំជក់ (កំណត់អាយុអប្បបរមា១៨ឆ្នាំ) | ក្រសួងមហាផ្ទៃ |
| ៣.២.៧- លើកទឹកចិត្តឱ្យមានការស្តារនីតិសម្បទានៅក្នុងសហគមន៍និងគ្រួសារ ជៀសវាងការបញ្ជូនកុមារទៅនៅក្នុងមណ្ឌល ស្ថាប័ន ចំពោះកុមារដែលត្រូវការស្តារនីតិសម្បទា | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.២.៨- ចាត់វិធានការឱ្យបានសមស្របដើម្បីលុបបំបាត់ការដាក់ពិន័យលើរាងកាយនិងផ្លូវចិត្តដល់សិស្សនិងកុមារ និងការណែនាំដល់គ្រូបង្រៀននិងនាយកសាលាមិនឱ្យមានការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ការឈ្លោះគ្នាក្នុងសាលា និងអំពើហិង្សាស្ងៀមស្ងាត់ចំពោះកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងអប់រំ យុវជន និងកីឡា |
| ៣.២.៩- ធ្វើឱ្យប្រសើរឡើងនូវគុណភាពមណ្ឌលស្តារនីតិសម្បទា និងមានសេវាពេញលេញសម្រាប់កុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.២.១០- បន្តអនុវត្តយុទ្ធសាស្ត្រចំណុចសំខាន់ៗស្តីពីការលុបបំបាត់កុមារប្រើប្រាស់គ្រឿងញៀនតាមរយៈការព្យាបាល ការអប់រំ និងស្តារនីតិសម្បទា ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀននិងសារធាតុគីមី | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងមហាផ្ទៃ |
| ៣.២.១១- រៀបចំកម្មវិធីបង្រៀន (ផ្តែកលើបទដ្ឋានអប្បបរមា) បណ្តុះបណ្តាលមន្ត្រីការងារសង្គមកិច្ច មន្ត្រីគ្រប់គ្រងមណ្ឌល ដើម្បីជួយដល់ក្រុមកុមារដែលបាត់បង់ឱកាស | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.២.១២- រៀបចំនិងផ្សព្វផ្សាយគោលការណ៍ណែនាំកិច្ចការពារកុមារ និងក្រមសីលធម៌នៃការការពារកុមារពីការរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទនៅក្នុងមណ្ឌលថែទាំកុមារនៅក្នុងសហគមន៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

**៣.៣- ចំណុចទី៣- អំពើជួញដូរលើកុមារត្រូវបានកាត់បន្ថយនិងលុបបំបាត់**

**លទ្ធផល:** ធ្វើការអង្កេតសិក្សាស្រាវជ្រាវដាច់ដោយឡែកពីគ្នា ស្តីពីអំពើជួញដូរកុមារនិងការធ្វើចំណាកស្រុក និងផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវទាំងពីរនេះឱ្យបានទូលំទូលាយនិងបង្កើតបទអន្តរាគមន៍នានា ដើម្បីដោះស្រាយបញ្ហាអំពើជួញដូរកុមារ ការចំណាកស្រុក និងការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ ។

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ៣.៣.១- ជួយសង្គ្រោះផ្ដល់ការប្រឹក្សាយោបល់ ស្ដារនីតិសម្បទានិងសមាហរណកម្មកុមាររងគ្រោះពីអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចផ្លូវភេទ និងទម្រង់ផ្សេងៗទៀតឱ្យទទួលបានសេវាថែទាំពេញលេញ ពិសេសកុមារី | ក្រសួងមហាផ្ទៃ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.៣.២- បន្តពង្រឹងការអនុវត្តច្បាប់នានាដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការការពារកុមារនិងកាត់បន្ថយអំពើជួញដូរកុមារ និងការកេងប្រវ័ញ្ចគ្រប់រូបភាព។ ហាមឃាត់កុមារបម្រើការងារនៅតាមវិស័យកម្សាន្តសប្បាយ និងទីកន្លែងគ្រឹះស្ថាននានាដែលមានស្ថានភាពពាក់ព័ន្ធនឹងអំពើជួញដូរកុមារ | ក្រសួងមហាផ្ទៃ |
| ៣.៣.៣- ពង្រឹងការអនុវត្តច្បាប់ គោលការណ៍ពាក់ព័ន្ធនានាទាក់ទងទៅនឹងការសុំកូនអន្តរប្រទេស ការជួញដូរសរីរាង្គកុមារ | ក្រសួងមហាផ្ទៃ |
| ៣.៣.៤- បង្កើតប្រព័ន្ធទិន្នន័យស្ដីពីការធ្វើចំណាកស្រុកកុមារ ដោយបែងចែក ភេទ អាយុឱ្យបានជាក់លាក់ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងផែនការ |
| ៣.៣.៥- ពង្រឹងការតាមដានត្រួតពិនិត្យប្រព័ន្ធយុត្តិធម៌អនីតិជន និងអំពើជួញដូរកុមារ | ក្រសួងយុត្តិធម៌ |
| ៣.៣.៦- បង្កើតយន្តការអប់រំសហគមន៍ស្ដីពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ពីវ័យក្មេងឱ្យបានទូលាយ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.៣.៧- បន្តការត្រួតពិនិត្យការធ្វើចំណាកស្រុករបស់កុមារនិងអំពើជួញដូរកុមារ និងបង្កើតអន្តរាគមន៍យុំគំរូគ្មានអំពើជួញដូរកុមារនិងការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងមហាផ្ទៃ |

**៣.៤- ចំណុចទី៤- បណ្ដាញសហគមន៍សិទ្ធិកុមារត្រូវបានបង្កើត**

**លទ្ធផល**: ៥០% នៃចំនួនឃុំ សង្កាត់ទូទាំងប្រទេស បានបង្កើតបណ្ដាញសហគមន៍សិទ្ធិកុមារ ដោយមានការចូលរួមពីអង្គការសង្គមស៊ីវិលនិងវិស័យឯកជន ដើម្បីការពារកុមាររាល់ទម្រង់ទាំងអស់ពីការកេងប្រវ័ញ្ចនិងអំពើហិង្សាលើកុមារ ។ លទ្ធផលនេះ គឺជានាថាឃុំ សង្កាត់ទាំងអស់នឹងបានបង្កើតបណ្ដាញឃុំ ដែលហៅថា *"បណ្ដាញឃុំដើម្បីសិទ្ធិកុមារ"* ក្នុងគោលបំណងទប់ស្កាត់ និងការពារកុមារឱ្យរួចផុតពីការកេងប្រវ័ញ្ចគ្រប់រូបភាពទាំងអស់នៅក្នុងសហគមន៍ អនុលោមតាមការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងកៀរគរអ្នកពាក់ព័ន្ធនានានិងវិស័យឯកជន ឱ្យមានការចូលរួមរាល់កិច្ចផ្ដួចផ្ដើមនេះ ។



ៗ

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ៣.៤.១- ធ្វើការផ្សព្វផ្សាយតាមសហគមន៍ និងការគាំទ្រការកសាងសមត្ថភាពស្តីពីសិទ្ធិកុមារ និងការទទួលខុសត្រូវរបស់សហគមន៍ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងមហាផ្ទៃ |
| ៣.៤.២- ពង្រឹងតួនាទីនិងការទទួលខុសត្រូវសហគមន៍ស្តីពី " កុមារមេត្រី " ដោយផ្តោតលើការផ្សព្វផ្សាយបញ្ហានានារបស់កុមារ និងលើកកម្ពស់សិទ្ធិកុមារក្នុងមណ្ឌលសុខភាពនិងតាមសហគមន៍ រួមទាំងបង្កើតកម្មវិធីផ្សព្វផ្សាយសម្រាប់អ្នកពាក់ព័ន្ធផ្សេងៗស្តីពីបញ្ហាកុមារ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.៤.៣- ផ្សព្វផ្សាយនិងពង្រឹងអាជ្ញាធរមូលដ្ឋាន មានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់និងមន្ត្រីនគរបាល ដោយជានាចាត់វិធានការដើម្បីការពារ<br>និងទប់ស្កាត់កុមារគ្រប់ៗរូបពីការកេងប្រវ័ញ្ចគ្រប់រូបភាព ព្រមទាំងផ្តល់សេវាកម្ម | ក្រសួងមហាផ្ទៃ |
| ៣.៤.៤- បង្កើនការផ្សព្វផ្សាយជាសាធារណៈ លើកកម្ពស់គោលនយោបាយរាជរដ្ឋាភិបាល ផ្តោតលើការអភិវឌ្ឍកុមារពិសេសរំលេចនូវបញ្ហាពលកម្មកុមារ អំពើជួញដូរ កុមារអនាថា និងទេសចរណ៍ផ្លូវភេទលើកុមារ និងរាល់បញ្ហានានាដែលពាក់ព័ន្ធនឹងកុមារ | ក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងព័ត៌មាន |
| ៣.៤.៥- ពង្រឹងការធ្វើសមាហរណកម្មឬបង្រួបបង្រួមកុមារដែលរស់នៅតាមស្ថាប័ន មណ្ឌល ឱ្យទៅរស់នៅជាមួយក្រុមគ្រួសារឬសាច់ញាតិវិញឬឪពុកម្តាយចិញ្ចឹម | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ៣.៤.៦- ជានាថាកាកបាទក្រហមកម្ពុជានិងសភាពាណិជ្ជកម្មកម្ពុជាបានកំណត់បញ្ហាកុមារទៅក្នុងផែនការយុទ្ធសាស្ត្រ និងផ្តល់សេវាគាំទ្រហិរញ្ញវត្ថុ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៣.៤.៧- ចាត់វិធានការតាមសហគមន៍ ប្រឆាំងនឹងជនប្រព្រឹត្តបទល្មើសលើការកេងប្រវ័ញ្ចលើកុមារ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.៤.៨- ជំរុញការអនុវត្តគោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |



៦

**យុទ្ធសាស្ត្រទី៤- ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតិបទដ្ឋានគតិយុត្តនិងគោលនយោបាយ**

គោលបំណង: ១)-ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការជាតិនិងអន្តរជាតិ តំបន់និងពិភពលោក ដើម្បីលើកកម្ពស់ និងការអនុវត្តអនុសាសន៍នានា ពិធីសារនានាស្តីពីការអភិវឌ្ឍកុមារ។ ២)-ពិនិត្យ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយនានា ដើម្បីធានាថាកុមារទទួលបាននូវកិច្ចការពារ និងផលប្រយោជន៍របស់កុមារ។

**៤.១- ចំណុចទី១- កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ត្រូវបានពង្រឹង**

**លទ្ធផល:** បង្កើនការគាំទ្រដល់កិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួង ស្ថាប័ន អង្គការ ដៃគូអភិវឌ្ឍ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងភ្នាក់ងារអង្គការសហប្រជាជាតិ។ លទ្ធផលនេះ គឺធានាដល់កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិគាំទ្រនិងការខិតខំប្រឹងប្រែងនានាដោះស្រាយរាល់បញ្ហានានារបស់កុមារ ដោយពង្រឹងកិច្ចសហប្រតិបត្តិការ ការពិភាក្សារាល់សកម្មភាពនានារវាងក្រសួង ស្ថាប័ន ទ្វេភាគី និងពហុភាគី។

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ៤.១.១- បង្កើតផែនទីបង្ហាញផ្លូវរបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍនានាក្នុងតំបន់ដែលមានកម្មវិធីឬអន្តរាគមន៍ផ្តោតលើកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៤.១.២- កៀរគរធនធានបច្ចេកទេស ថវិកានិងការគាំទ្រពីក្រសួង ស្ថាប័ន អង្គការដៃគូនានា និងភ្នាក់ងារអង្គការសហប្រជាជាតិសម្រាប់កម្មវិធីក្នុងការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៤.១.៣- រៀបចំសកម្មភាពការងារអន្តរក្រសួង ស្ថាប័ន(ថ្នាក់ជាតិនិងក្រោមជាតិ) និងអាស៊ានដើម្បីលើកកម្ពស់សិទ្ធិកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |
| ៤.១.៤- លើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដាក់បញ្ចូលអនុសាសន៍អង្គការសហប្រជាជាតិ លិខិតូបករណ៍អន្តរជាតិ និងសេចក្តីប្រកាសនានាទៅក្នុងផែនការតាមវិស័យ និងតាមដានការអនុវត្តប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |
| ៤.១.៥- ពិនិត្យ បង្កើតនិងអនុវត្តអនុស្សរណៈជាមួយដៃគូអភិវឌ្ឍប្រទេសផ្សេងៗក្នុងតំបន់លើបញ្ហាទាំងអស់ពាក់ព័ន្ធនឹងកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្រសួងការ<br>ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ |



៦

| | |
|---|---|
| ៤.១.៦- កែលម្អរាល់វិធានការច្បាប់ទាំងឡាយរបស់ជាតិឱ្យមានសង្គតិភាព (ភាពស៊ីចង្វាក់គ្នា) ជាមួយនឹងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិពាក់ព័ន្ធនឹងកុមារ | ក្រសួងយុត្តិធម៌ |
| **៤.២- ចំណុចទី២- ក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានពង្រឹងការអនុវត្ត**<br>**លទ្ធផល:** ពិនិត្យនិងជំរុញការអនុវត្តក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីកុមារ ។ លទ្ធផលនេះ ធានាការអនុវត្តច្បាប់ ឬការធ្វើវិសោធនកម្ម ដោយផ្អែកលើការវិភាគនិងតម្រូវការ ដោយរួមបញ្ចូលការបង្កើត ការអនុវត្ត និងការផ្សព្វផ្សាយ គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងប្រកាសពាក់ព័ន្ធនឹងការលើកកម្ពស់សិទ្ធិកុមារ។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ៤.២.១- ពិនិត្យបញ្ចូលសិទ្ធិនិងសេវាបន្ថែមសម្រាប់កុមារនិងសេវាកម្មនានា សម្រាប់ក្រុមកុមារដែលបាត់បង់ឱកាស | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៤.២.២- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីធានាថា សេវានិងការថែទាំសុខភាព (រួមទាំងមនុស្សពេញវ័យ) ដូចជាកុមារពិការរួមទាំងសេវានិងការថែទាំផ្នែកស្មារតីត្រូវបានផ្តល់ជូនដោយឥតបង់ថ្លៃ និងមិនមានការបង្ខិតបង្ខំឱ្យទទួលការព្យាបាលឬមានការឃុំឃាំងឡើយ | រដ្ឋសភា<br>ក្រសួងសុខាភិបាល |
| ៤.២.៣- ពិនិត្យបញ្ចូលបញ្ញត្តិក្នុងច្បាប់ឬបទដ្ឋានគតិយុត្តនានា ធានាថា ពលកម្មកុមារតាមវិស័យមិនផ្លូវការទទួលបានសិទ្ធិនិងការការពារដូចអ្នកធ្វើការក្នុងវិស័យផ្លូវការ ពិសេសពាក់ព័ន្ធទៅនឹងប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារ | ក្រសួងយុត្តិធម៌<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៤.២.៤- វិសោធនកម្មច្បាប់ការងារស្តីពីការងារបម្រើតាមផ្ទះ រួមទាំងបញ្ញត្តិស្តីពីកម្មករកុមារបម្រើតាមផ្ទះ | ក្រសួងយុត្តិធម៌<br>ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៤.២.៥- រៀបចំកំណត់ពន្យល់ស្តីពីច្បាប់ទេសចរណ៍ និងកំណត់មនុស្សពេញវ័យសម្រាប់ចូលមណ្ឌលកម្សាន្ត។ ធានាកុមារអាយុក្រោម១៨ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារឬចូលក្នុងកន្លែងកម្សាន្តសម្រាប់មនុស្សពេញវ័យឡើយ | ក្រសួងទេសចរណ៍<br>ក្រសួងយុត្តិធម៌ |
| ៤.២.៦- ពិនិត្យនិងដាក់បញ្ចូលរាល់បញ្ហារបស់កុមារទៅក្នុងប្រព័ន្ធគោលនយោបាយនិងផែនការឃុំ សង្កាត់ | ក្រសួងមហាផ្ទៃ |
| ៤.២.៧- រៀបចំអនុក្រឹត្យស្តីពីកិច្ចការពារកុមារ និងក្រមសីលធម៌ការការពារកុមារ និងផ្សព្វផ្សាយ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៤.២.៨- ជំរុញការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជននិងបទដ្ឋានគតិយុត្តនានាដែលពាក់ពន្ធ័នឹងសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព | ក្រសួងយុត្តិធម៌<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | |
|---|---|
| ៤.២.៩- ពិនិត្យនិងកំណត់ទៅលើអាយុអប្បបរមាសម្រាប់ការងារនៅក្នុងលក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់ អនុលោមទៅតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៤.២.១០- រៀបចំបញ្ញត្តិកុមារញៀនគ្រឿងញៀនឱ្យទទួលបានការព្យាបាលនិងស្តារនីតិសម្បទា នៅតាមគ្រួសារនិងតាមសហគមន៍។ វិធានការចុងក្រោយ ត្រូវយកកុមារគ្រឿងញៀនដាក់ក្នុងមណ្ឌលស្តារនីតិសម្បទា និងដាក់នៅដាច់ដោយឡែកពីមនុស្សពេញវ័យ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ក្រសួងសុខាភិបាល |

**យុទ្ធសាស្ត្រទី៥- ពង្រឹងយន្តការជាតិនិងសមត្ថភាពបំពេញមុខងារឱ្យមានដំណើរការល្អ**

គោលបំណង: ១)-ធានាឱ្យមានសមត្ថភាពដឹកនាំ សម្របសម្រួលការត្រួតពិនិត្យតាមដាន និងការសរសេររបាយការណ៍ប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។ ២)-អភិវឌ្ឍន៍សមត្ថភាពមន្ត្រីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

**៥.១- ចំណុចទី១- ពង្រឹងការសម្របសម្រួល ការត្រួតពិនិត្យ និងការសរសេររបាយការណ៍**

**លទ្ធផល:** យន្តការសម្របសម្រួលរបស់ *ក.ជ.ក.* ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានពង្រឹង និងបំពេញមុខងារឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការដឹកនាំ សម្របសម្រួល និងការអនុវត្តសកម្មភាពនានាប្រកបដោយប្រសិទ្ធផល។ លទ្ធផលរំពឹងទុកនេះធានាថា យន្តការ *ក.ជ.ក.* នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានដឹកនាំនិងដំណើរការ រួមទាំងការសម្របសម្រួលការតាមដានរាល់ស្ថានភាពនានារបស់កុមារ និងការរៀបចំរបាយការណ៍។ លិខិតបទដ្ឋានគតិយុត្តនានានានាដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ *ក.ជ.ក.* នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិត្រូវបានបង្កើតនិងផ្សព្វផ្សាយ។ បង្កើនប្រសិទ្ធភាពការកៀរគរថវិកាជាតិនិងអង្គការដៃគូអភិវឌ្ឍ ដើម្បីគាំទ្រដល់កម្មវិធីឬគម្រោងក្នុងការអភិវឌ្ឍកុមារ។

| សកម្មភាព | ក្រសួង ស្ថាប័នដឹកនាំអនុវត្ត |
|---|---|
| ៥.១.១- ពង្រឹងយន្តការ ក.ជ.ក. ថ្នាក់ក្រោមជាតិក្នុងការដឹកនាំ សម្របសម្រួលការងារជាអន្តរវិស័យ ដើម្បីលើកកម្ពស់និងការពារសិទ្ធិកុមារ | ក្រសួងមហាផ្ទៃ<br>ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥.១.២- ពង្រឹងនិងពង្រីកការបង្កើតក្រុមការងារដើម្បីកុមារតាមក្រសួង ស្ថាប័ន | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥.១.៣- បង្កើតយន្តការទទួលពាក្យបណ្តឹង និងការប្រើប្រាស់យន្តការនេះឱ្យមានលក្ខណៈងាយស្រួល | ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥.១.៤- សម្របសម្រួលបណ្តាញទូរសព្ទទាន់ហេតុការណ៍ សម្រាប់ដោះស្រាយបញ្ហាកុមារឱ្យមានប្រសិទ្ធភាពទូទាំង២៥ រាជធានី ខេត្ត | ក្រសួងមហាផ្ទៃ |

| | |
|---|---|
| ៥.១.៥- បង្កើតយន្តការពិនិត្យ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការអង្គការដៃគូ ទាំងថវិកានិងបច្ចេកទេសសម្រាប់រាល់គម្រោងកម្មវិធីពាក់ព័ន្ធនឹងកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥.១.៦- បង្កើតប្រព័ន្ធត្រួតពិនិត្យតាមដាននៅ ក.ជ.ក. ដើម្បីពិនិត្យវឌ្ឍនភាពនិងភាពខ្វះចន្លោះនានា ក្នុងលើកកម្ពស់ការអភិវឌ្ឍកុមារ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៥.២- ចំណុចទី២- ការបង្កើននិងអភិវឌ្ឍសមត្ថភាព**<br>**លទ្ធផល:** មន្ត្រី ***ក.ជ.ក.*** ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានបង្កើនចំណេះដឹងទាក់ទងច្បាប់ គោលនយោបាយ កម្មវិធី ឬគម្រោងជាតិស្តីពីការអភិវឌ្ឍកុមារ។ លទ្ធផលនេះជានាថាមន្ត្រី ***ក.ជ.ក.*** ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិបានបង្កើនសមត្ថភាពលើគោលនយោបាយ ច្បាប់ អនុសញ្ញាអន្តរជាតិ និងកម្មវិធីនានា និងការយល់ដឹងពីនិន្នាការ និងស្ថានភាពរបស់កុមារ និងសំដៅរៀបចំកម្មវិធីឆ្លើយតប ។ | |
| **សកម្មភាព** | **ក្រសួង ស្ថាប័នដឹកនាំអនុវត្ត** |
| ៥.២.១- ពិនិត្យសមាសភាព តួនាទី ភារកិច្ច និងការទទួលខុសត្រូវគាំទ្រដល់ការបំពេញមុខងារសកម្មរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានី ខេត្តឱ្យមានដំណើរការល្អ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥.២.២- បង្កើនសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋាននៃ ក.ជ.ក. ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើជំនាញគ្រប់គ្រងកម្មវិធីភាពជាអ្នកដឹកនាំ ការសម្របសម្រួល ការវិភាគ និងការសរសេររបាយការណ៍ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥.២.៣- ពង្រឹងសមត្ថភាពនិងការចូលរួមពីមន្ត្រីគ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានា ក្នុងការងារស្តីពីលើកកម្ពស់សិទ្ធិកុមារ និងការងារពាក់ព័ន្ធទៅនឹងច្បាប់ គោលនយោបាយជាតិ អនុសញ្ញាអន្តរជាតិ ពិធីសារបន្ថែម និងការលើកកម្ពស់សិទ្ធិកុមារ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| ៥.២.៤- លើកកម្ពស់វិជ្ជាជីវៈនិងក្រមសីលធម៌របស់អ្នកទទួលខុសត្រូវដែលពាក់ពន្ធ័នឹងកុមារគ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងក្រោមជាតិ និងជាមួយអង្គការដៃគូអភិវឌ្ឍ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ<br>ទីស្តីការគណៈរដ្ឋមន្ត្រី |

# ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

| យុទ្ធសាស្ត្រទី១- លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាលជំនាញ | | | | |
|---|---|---|---|---|
| **អន្តរាគមន៍** | **ចំណុចដៅលទ្ធផល** | **២០១៦** | **២០១៧** | **២០១៨** |
| *១.១- លើកកម្ពស់ការអភិវឌ្ឍកុមារតូច* | ១. កុមារអាយុ៣-៥ឆ្នាំ ៥៥% ចូលរៀនមត្តេយ្យសិក្សា | ៤៦ | ៥១ | ៥៥ |
| | ២. សាលារៀនមត្តេយ្យសិក្សា៩០%សម្រេចបានស្តង់ដាគុណភាពសិក្សា | | | ៩០ |
| | | | | |
| *១.២- លើកកម្ពស់ការអប់រំនៅតាមសាលារៀននៅគ្រប់កម្រិតសិក្សា* | ១. អត្រាពិតនៃការសិក្សានៅបឋមសិក្សា (សរុប) | ១០០ | ១០០ | ១០០ |
| | ២. អត្រាពិតនៃការសិក្សានៅបឋមសិក្សា (ស្រី) | ១០០ | ១០០ | ១០០ |
| | ៣. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (សរុប) | ៧៤ | ៨១ | ៨៧ |
| | ៤. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | ៧៣ | ៨០ | ៨៦ |
| | ៥. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (សរុប) | ៣៤ | ៣៨ | ៤៥ |
| | ៦. អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ស្រី) | ៣២ | ៣៦ | ៤២ |
| | ៧. អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (សរុប) | ១០០ | ១០០ | ១០០ |
| | ៨. អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (ស្រី) | ១០០ | ១០០ | ១០០ |
| | ៩. អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (សរុប) | ៥៧ | ៦៧ | ៧៦ |
| | ១០. អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ស្រី) | ៥៧ | ៦៧ | ៧៦ |
| | ១១. ភាគរយកុមារអាយុ៦-១៧ឆ្នាំក្នុងការសិក្សា | >៨០.២ | >៨០.២ | >៨០.២ |
| | ១២. ចំនួនកុមារអាយុ៦-១៧ឆ្នាំ មិននៅក្នុងការសិក្សាឬកម្លាំងពលកម្ម | | | ០ |
| | ១៣. ចំនួនសាលារៀនសម្រាប់កុមារងាយរងគ្រោះ | * | * | * |
| | | | | |
| *១.៣- ពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ* | ១. ចំនួនកុមារអាយុ១១ដល់ក្រោម១៨ឆ្នាំ ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈឬបច្ចេកទេស | | | |
| | ២. ចំនួនខេត្តដែលមានមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស | ១២ | ២០ | ២៥ |
| | ៣. ភាគរយកុមារអាយុ១១ដល់ក្រោម១៨ឆ្នាំសិក្សានៅតាមសាលារៀនបច្ចេកទេសធៀបនឹងចំនួនកុមារសរុបក្នុងក្រុមអាយុនេះ | | | |

## យុទ្ធសាស្ត្រទី២- លើកកម្ពស់សុខុមាលភាពសង្គមសម្រាប់កុមារ

| អន្តរាគមន៍ | ចំណុចដៅលទ្ធផល | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| *២.១- ពង្រឹងស្ថានភាពសេដ្ឋកិច្ចគ្រួសារ និងសុខុមាលភាពសង្គមរបស់កុមារ* | ១. អត្រាភាពក្រីក្រជាតិ | ១៤.៨ | ១៣.៨ | ១២.៨ |
| | ២. អត្រាភាពក្រីក្រកុមារ | ១៩.៥ | ១៨.៥ | ១៧.៥ |
| | ៣. សន្ទស្សន៍ភាពក្រីក្រកុមារមានច្រើនប្រភេទ | ៥៣.៤ | ៥២.៤ | ៥១.៤ |
| | ៤. ចំនួនគ្រួសារក្រីក្រដែលគ្មានដីធ្លីទទួលបានការបែងចែងដីសម្បទានសង្គមកិច្ច | >៣១,០០០ | >៣១,០០០ | >៣១,០០០ |
| | ៥. ភាគរយកុមារអាយុក្រោម១៨ឆ្នាំ ដែលរស់នៅតែម្នាក់ឯង | <៧,០០០ | <៧,០០០ | <៧,០០០ |
| | | | | |
| *២.២-លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ* | ១. អត្រាមរណទារក | <២៨ | <២៨ | <២៨ |
| | ២. អត្រាមរណកុមារអាយុក្រោម៥ឆ្នាំ | <៣៥ | <៣៥ | <៣៥ |
| | ៣. ភាគរយកុមារអាយុក្រោម១ឆ្នាំទទួលបានវ៉ាក់សាំងគ្រប់មុខ | ៩៥ | ៩៥ | ៩៥ |
| | ៤. ភាគរយកុមារអាយុក្រោម៥ឆ្នាំដែលមានទម្ងន់ក្រោមស្តង់ដា(មានទម្ងន់ទាប) មធ្យមឬធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងអាយុតិចជាង២នៃបម្រែបម្រួលស្តង់ដាក្រោមតម្លៃធម្មតា) | <២៣.៩ | <២៣.៩ | <២៣.៩ |
| | | | | |
| *២.៣- លើកកម្ពស់លំនៅឋាន ទឹកស្អាត និងអនាម័យ* | ១. ភាគរយគ្រួសាររស់នៅក្នុងផ្ទះដែលមានដំបូលស្បូវ | <៦.៥ | <៦.៥ | <៦.៥ |
| | ២. ភាគរយប្រជាជនដែលទទួលបានទឹកស្អាតនៅជនបទ | ៥០ | ៦០ | ៦៧ |
| | ៣. ភាគរយប្រជាជនដែលទទួលបានទឹកស្អាតនៅប្រជុំជន | ៨០ | ៨៣ | ៨៥ |
| | ៤. ភាគរយគ្រួសារដែលទទួលបានអនាម័យប្រសើរជាងមុននៅជនបទ | ៥២ | ៥៥ | ៦០ |
| | ៥. ភាគរយគ្រួសារដែលទទួលបានអនាម័យប្រសើរជាងមុននៅទីប្រជុំជន | >៨០ | >៨០ | >៨០ |

## យុទ្ធសាស្ត្រទី៣- ពង្រឹងការការពារកុមារនិងការបង្ការទប់ស្កាត់

| អន្តរាគមន៍ | ចំណុចដៅលទ្ធផល | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| *៣.១- លុបបំបាត់ពលកម្មកុមារ* | ១. ភាគរយពលកម្មកុមារអាយុក្រោម៧ឆ្នាំ (ប្រុស) | <៩.៣ | <៩.៣ | <៨ |
| | ២. ភាគរយពលកម្មកុមារអាយុក្រោម៧ឆ្នាំ (ស្រី) | <១០.៧ | <១០.៧ | <៨ |
| | ៣. ផែនការសកម្មភាពជាតិលុបបំបាត់ពលកម្មកុមារ ទី២ | អនុម័តនៅឆ្នាំ២០១៦ | | |
| | ៤. កម្មវិធីផ្ទេរសាច់ប្រាក់ | ចាប់ផ្តើមនៅឆ្នាំ២០១៧ | | |

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| *៣.២- កាត់បន្ថយអំពើហិង្សាលើកុមារ និងគ្រឿងញៀន* | ១. ផែនការសកម្មភាពពហុវិស័យសម្រាប់អំពើហិង្សាលើកុមារត្រូវបានរៀបចំឡើងនិងអនុវត្ត | រៀបចំនៅឆ្នាំ២០១៦និងអនុវត្តនៅឆ្នាំ២០១៨ | | | |
| | ២. ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃសម្រាប់អំពើហិង្សាលើកុមារត្រូវបានដាក់ឱ្យដំណើរការ | ដំណើរការនៅឆ្នាំ២០១៦ | | | |
| | ៣. ច្បាប់និងបទប្បញ្ញត្តិនានាស្តីពីការត្រួតពិនិត្យគ្រឿងស្រវឹង ត្រូវបានអនុម័ត | អនុម័តនៅឆ្នាំ២០១៦ | | | |
| | ៤. អនុក្រឹត្យស្តីពីកិច្ចការពារកុមារ និងក្រមសីលធម៌ការពារកុមារ | រៀបចំនៅឆ្នាំ២០១៦ | | | |
| | ៥. ច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័ត | គ្រោងដាក់ជូនអនុម័តនៅឆ្នាំ២០១៧ | | | |
| | | | | | |
| *៣.៣- ការលុបបំបាត់ការជួញដូរកុមារ* | ១. យន្តការទប់ស្កាត់ការជួញដូរកុមារដំណើរការពេញលេញនៅតាមរាជធានី ខេត្ត | ដំណើរការនៅឆ្នាំ២០១៦ | | | |
| | ២. ភាគរយឃុំ សង្កាត់ដែលមានស្ថាប័នផ្តល់សេវាកម្មដល់កុមារកំព្រានិងកុមាររងគ្រោះ | | ៨០ | ៩០ | ១០០ |
| | ៣. ទិន្នន័យស្តីពីកុមារផ្លាស់ប្តូរលំនៅឋានក្នុងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់កុមារ | ដំណើរការនៅឆ្នាំ២០១៧ | | | |
| | ៤. ទិន្នន័យកុមារកំព្រាត្រូវបានរៀបចំឡើងនៅក្នុងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់កុមារនិងដំណើរការពេញលេញ | ដំណើរការនៅឆ្នាំ២០១៧ | | | |
| | ៥. ការសិក្សាស្រាវជ្រាវយ៉ាងតិច២ករណី ត្រូវបានរៀបចំឡើងស្តីពីការផ្លាស់ប្តូរលំនៅឋាន និងធ្វើការផ្សព្វផ្សាយ | ការសិក្សាស្រាវជ្រាវត្រូវបានបញ្ចប់និងផ្សព្វផ្សាយនៅឆ្នាំ២០១៧ | | | |
| | | | | | |
| *៣.៤- បណ្តាញសហគមន៍សម្រាប់ការពារសិទ្ធិកុមារ* | ១. ចំនួនកុមារអាយុតិចជាង១៨ឆ្នាំដែលមានសំបុត្របញ្ជាក់កំណើត | | | | ទាំងអស់ |
| | ២. ចំនួនកុមារសុំកូនចិញ្ចឹមនៅតាមគ្រួសារ | | | | |
| | ៣. ចំនួនឃុំដែលបានបង្កើតបណ្តាញសហគមន៍សម្រាប់ការពារសិទ្ធិកុមារពីការធ្វើអាជីវកម្មផ្សេងៗ | | | | ៨១៤ |
| | | | | | |
| **យុទ្ធសាស្ត្រទី៤- ពង្រឹងកិច្ចសហប្រតិបត្តិការ ការអនុវត្តលិខិតិបទដ្ឋានគតិយុត្តនិងគោលនយោបាយ** | | | | | |
| *៤.១- កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ* | ១. ច្បាប់ពាក់ព័ន្ធនឹងកុមារត្រូវបានអនុម័តដើម្បីបំពេញស្តង់ដាអាស៊ាន | នៅឆ្នាំ២០១៨ | | | |
| | ២. កម្ពុជាឆ្លើយតបនឹងកាតព្វកិច្ចផ្លូវការចាំបាច់នានារបស់អង្គការសហប្រជាជាតិ | នៅឆ្នាំ២០១៨ | | | |
| *៤.២- ពង្រឹងការអនុវត្តច្បាប់និងគោលនយោបាយ* | **ច្បាប់ត្រូវបានអនុម័តឬធ្វើវិសោធនកម្មទាក់ទងនឹង៖** | | | | |
| | • ពលកម្មកុមារក្នុងការងារដែលមានគ្រោះថ្នាក់ | បញ្ចប់នៅឆ្នាំ២០១៧ | | | |
| | • សិទ្ធិកុមារពិការ | បញ្ចប់នៅឆ្នាំ២០១៧ | | | |
| | • ការងារតាមផ្ទះ | បញ្ចប់នៅឆ្នាំ២០១៧ | | | |

| | | |
|---|---|---|
| | • យុត្តិធម៌របស់កុមារ | បញ្ចប់នៅឆ្នាំ២០១៧ |
| | • ការលក់គ្រឿងស្រវឹងនិងផលិតផលថ្នាំជក់ដល់ប្រជាជនអាយុលើស១៨ឆ្នាំ | បញ្ចប់នៅឆ្នាំ២០១៧ |
| | • ការកំណត់ទីតាំងកម្សាន្ត | បញ្ចប់នៅឆ្នាំ២០១៦ |
| | • នីតិវិធីបណ្តឹងនិងសិទ្ធិកុមារ តាមអនុសាសន៍របស់អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ | បញ្ចប់នៅឆ្នាំ២០១៦ |
| | | |
| **យុទ្ធសាស្ត្រទី៥- ពង្រឹងយន្តការជាតិ សមត្ថភាព និងដំណើរការ** | | |
| *៥.១- ពង្រឹងការសម្របសម្រួល ការត្រួតពិនិត្យនិងការសរសេររបាយការណ៍* | ១. ការិយាល័យ ក.ជ.ក. ត្រូវបានបង្កើតឡើង | បញ្ចប់នៅឆ្នាំ២០១៨ |
| | ២. ទូរសព្ទទាន់ហេតុការណ៍ទាក់ទងនឹងកុមារត្រូវបានបង្កើតឡើងនៅតាមបណ្តា ខេត្តមួយចំនួន | បញ្ចប់នៅឆ្នាំ២០១៨ |
| | ៣. បញ្ចប់ការកែសម្រួលគោលនយោបាយនានាទាក់ទងនឹងកុមារ | បញ្ចប់នៅឆ្នាំ២០១៧ |
| *៥.២- ការបង្កើននិងអភិវឌ្ឍន៍សមត្ថភាព* | ១. សមាជិករបស់ ក.ជ.ក. ទទួលបានការបណ្តុះបណ្តាលស្តីពីបញ្ហាកុមារ | បញ្ចប់នៅឆ្នាំ២០១៦ |

# សូចនាករសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់រាជធានី ខេត្ត

| អន្តរាគមន៍ | ចំណុចដៅលទ្ធផល | ២០១៦ | ២០១៧ | ២០១៨ |
|---|---|---|---|---|
| *លើកកម្ពស់ការអភិវឌ្ឍកុមារតូច* | ១. កុមារអាយុ៣-៥ឆ្នាំ ៥៥% ចូលរៀនមត្តេយ្យសិក្សា | | | |
| | | | | |
| *លើកកម្ពស់ការអប់រំនៅតាមសាលារៀននៅគ្រប់កម្រិតសិក្សា* | ១. អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (សរុប) | | | |
| | ២. អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (សរុប) | | | |
| | | | | |
| *ពង្រីកការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារ* | ១. ចំនួនរាជធានី ខេត្តដែលមានមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស | | | |
| | | | | |
| **អន្តរាគមន៍** | **ចំណុចដៅលទ្ធផល** | **២០១៦** | **២០១៧** | **២០១៨** |
| *ពង្រឹងស្ថានភាពសេដ្ឋកិច្ចគ្រួសារនិងសុខុមាលភាពសង្គមរបស់កុមារ* | ១. អត្រាភាពក្រីក្រជាតិ | | | |
| | ២. ភាគរយកុមារអាយុក្រោម១៨ឆ្នាំ ដែលរស់នៅតែម្នាក់ឯង | | | |
| | | | | |
| *លើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ* | ១. អត្រាមរណៈទារក | <២៨ | <២៨ | <២៨ |
| | ២. អត្រាមរណៈកុមារអាយុក្រោម៥ឆ្នាំ | <៣៥ | <៣៥ | <៣៥ |
| | ៣. ភាគរយកុមារអាយុក្រោម១ឆ្នាំទទួលបានវ៉ាក់សាំងគ្រប់មុខ | ៩៥ | ៩៥ | ៩៥ |
| | ៤. ភាគរយកុមារអាយុក្រោម៥ឆ្នាំដែលមានទម្ងន់ក្រោមស្តង់ដា(មានទម្ងន់ទាប) មធ្យមឬធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងអាយុតិចជាង២នៃបម្រែបម្រួលស្តង់ដាក្រោមតម្លៃធម្មតា) | <២៣.៩ | <២៣.៩ | <២៣.៩ |
| | | | | |
| *លើកកម្ពស់លំនៅឋាន ទឹកស្អាត និងអនាម័យ* | ១. ភាគរយគ្រួសាររស់នៅក្នុងផ្ទះដែលមានដំបូលសង្ស័រ | | | |
| | ២. សមាមាត្រប្រជាជនដែលទទួលបានទឹកស្អាត | | | |
| | ៣. សមាមាត្រគ្រួសារដែលទទួលបានអនាម័យប្រសើរជាងមុន | | | |
| | | | | |
| *បណ្តាញសហគមន៍ ការពារសិទ្ធិកុមារ* | ១. ចំនួនកុមារអាយុតិចជាង១៨ឆ្នាំដែលមានសំបុត្របញ្ជាក់កំណើត | | | |
| | ២. ចំនួនកុមារចិញ្ចឹមនៅតាមគ្រួសារ | | | |
| | ៣. ចំនួនឃុំដែលបានបង្កើតបណ្តាញសហគមន៍សម្រាប់ការពារសិទ្ធិកុមារពីការធ្វើអាជីវកម្មផ្សេងៗ | | | |

# ៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់-លិខិតបទដ្ឋានគតិយុត្ត

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវពិនិត្យឡើងវិញរាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងកុមារ ហើយលើកសំណើទៅក្រសួង ស្ថាប័នជំនាញ ដើម្បីធ្វើវិសោធនកម្មឬកែសម្រួលលិខិតបទដ្ឋានដែលមានចំណុចខ្វះចន្លោះ រៀបចំលិខិតបទដ្ឋានគតិយុត្តថ្មី និងផ្តល់យោបល់ដល់បណ្តាក្រសួង ស្ថាប័ននានា ព្រមទាំងសុំសច្ចាប័នលើកិច្ចព្រមព្រៀង អនុសញ្ញា ពិធីសារដែលទាក់ទងនឹងកុមារ។

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងកុមារមានដូចខាងក្រោម៖

- ពិនិត្យនិងស្នើសុំការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- រៀបចំអនុក្រឹត្យស្តីពីកិច្ចការពារកុមារ
- រៀបចំក្រមសីលធម៌ការពារកុមារ
- ផ្សព្វផ្សាយអនុក្រឹត្យស្តីពីកិច្ចការពារកុមារ និងក្រមសីលធម៌ការពារកុមារ
- រៀបចំកំណត់ពន្យល់ច្បាប់ស្តីពីទេសចរណ៍ និងការកំណត់មនុស្សពេញវ័យសម្រាប់ចូលមណ្ឌលកម្សាន្ត។ ជានាថាកុមារអាយុក្រោម១៨ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការងារឬចូលក្នុងកន្លែងកម្សាន្តសម្រាប់មនុស្សពេញវ័យឡើយ
- វិសោធនកម្មច្បាប់ស្តីពីការងារពាក់ព័ន្ធនឹងការងារបម្រើតាមផ្ទះ រួមទាំងបញ្ញត្តិស្តីពីកម្មករកុមារបម្រើតាមផ្ទះ
- ពិនិត្យនិងកំណត់ទៅលើអាយុអប្បបរមាសម្រាប់ការងារនៅក្នុងលក្ខខណ្ឌប្រកបដោយគ្រោះថ្នាក់ អនុលោមទៅតាមអនុសញ្ញាអង្គការពលកម្មអន្តរជាតិ
- រៀបចំឱ្យមានបទប្បញ្ញត្តិទាក់ទងកុមារញៀនគ្រឿងញៀនសម្រាប់ព្យាបាលនិងស្តារនីតិសម្បទា
- រៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីធានាថា សេវានិងការថែទាំសុខភាពត្រូវបានផ្តល់ជូនដោយឥតបង់ថ្លៃ និងមិនមានការបង្ខិតបង្ខំឱ្យទទួលការព្យាបាលឬមានការឃុំឃាំងឡើយ។

(ចំពោះកាលវិភាគនៃការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិមានក្នុងតាមម៉ាទ្រិចចំណុច៤.២)

# ៥- គម្រោងចំណាយ

ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ(**ផ.ជ.អ.ក.**)។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវផ្តល់ការសម្របសម្រួលជាចាំបាច់ដល់ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការទំនាក់ទំនងក្នុងការរៀបចំផែនការជាមួយនឹងមន្ទីរពាក់ព័ន្ធនានា ដើម្បីដាក់បញ្ចូលសកម្មភាពនៃផែនការសកម្មភាពជាតិនេះទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំតាមក្រសួង ស្ថាប័ននីមួយៗ។ ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានកិច្ចសហការជាអន្តរក្រសួង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាអ្នកធ្វើការសម្របសម្រួលកិច្ចសហការនេះតាមរយៈក្រុមការងារដើម្បីកុមារ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងពង្រឹងពង្រីកការិយាល័យពិនិត្យតាមដាននិងរបាយ-ការណ៍ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ។

រាល់ការចំណាយនានាដើម្បីអនុវត្តសកម្មភាពនៅក្នុង **ផ.ជ.អ.ក.** នឹងត្រូវមានដាក់បញ្ចូលតាមផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងលើកសំណើថវិកាសម្រាប់ការងារត្រួតពិនិត្យតាមដាន វាយតម្លៃ ការសម្របសម្រួល និងការសរសេររបាយការណ៍។ ដៃគូអភិវឌ្ឍនានា គាំទ្រប្រភពធនធានដល់ដំណើរការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ។

# ៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារឆ្នាំ២០១៦-២០១៨ ត្រូវធ្វើការតាមដានត្រួតពិនិត្យនិងការវាយតម្លៃប្រចាំឆ្នាំតាមសកម្មភាពនីមួយៗ។ ផែនការនេះ នឹងជួយដល់អ្នករៀបចំផែនការសកម្មភាពនិងភ្នាក់ងារប្រតិបត្តិនានា នូវការវាយតម្លៃអំពីវឌ្ឍនភាពដែលសម្រេចបានតាមសកម្មភាពនិងវិស័យពាក់ព័ន្ធទាំងអស់។ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារនេះ រួមមាន៖

១- ការផ្តោតលើសមិទ្ធផលសម្រេច។
២- ការពង្រឹងសមត្ថភាពមន្ត្រីនិងអ្នកពាក់ព័ន្ធទទួលយកការគ្រប់គ្រងទិន្នន័យនិងការវិភាគ។
៣- ការចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិលពាក់ព័ន្ធផ្សេងៗទៀតដែលសម្របសម្រួលដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។
៤- ការវាយតម្លៃអំពីវឌ្ឍនភាពប្រចាំឆ្នាំនៃការអនុវត្តផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ។

## ៦.១- វិធីសាស្ត្រ

ក.ជ.ក. ត្រូវពង្រឹងការិយាល័យពិនិត្យតាមដាននិងវាយតម្លៃ ដើម្បីវាយតម្លៃលទ្ធផលនានាពាក់ព័ន្ធនឹងកុមារ ការងារដែលការិយាល័យត្រូវទទួលខុសត្រូវ គឺជួយប្រមូលទិន្នន័យ និងពិនិត្យលើលទ្ធផលដែលសម្រេចបានទាំងបរិមាណនិងគុណភាពពាក់ព័ន្ធទៅនឹងគោលដៅកំណត់នៅក្នុងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ។ លើសពីនេះទៅទៀត ដំណើរការការតាមដានត្រួតពិនិត្យនិងវាយតម្លៃចាំបាច់បង្ហាញពីភស្តុតាងជាក់លាក់ ក៏ដូចជាដំណើរការបង្ហាញពីប្រភពនៃលទ្ធផលស្តីពីលទ្ធផលសូចនាករដែលបានកំណត់ជាចាំបាច់សម្រាប់ធ្វើផែនការនិងកម្មវិធី។

ក្នុងការអនុវត្ត ការពិនិត្យចង្វាក់លទ្ធផលជាកត្តាជាក់ស្តែងទៅតាមបរិបទនិងកត្តាហានិភ័យនានា គឺជាការទទួលខុសត្រូវរបស់ភ្នាក់ងារអនុវត្ត។ ក.ជ.ក. គឺជាភ្នាក់ងារកណ្តាល មិនជាភ្នាក់ងារអនុវត្តកម្មវិធីនៅតាមមូលដ្ឋាននោះទេ ហើយការិយាល័យពិនិត្យតាមដាននិងវាយតម្លៃនឹងមិនតាមដានត្រួតពិនិត្យធាតុចូល ដំណើរការនិងសូចនាករធាតុចេញទេ លើកលែងតែក្នុងករណីចាំបាច់មួយចំនួនប៉ុណ្ណោះ។

ដូច្នេះ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃទៅតាមកម្រិតក្រសួង ស្ថាប័នរបស់ខ្លួនដែលត្រូវតាមដានត្រួតពិនិត្យនិងវាយតម្លៃទៅតាមសូចនាករលទ្ធផលនិងផលប៉ះពាល់។ នៅកម្រិតម៉ាក្រូ និងថ្នាក់ក្រោមជាតិ ត្រូវវាយតម្លៃអំពីវឌ្ឍនភាពដែលសម្រេចបាននិងវាយតម្លៃផលប៉ះពាល់លើសុខុមាលភាពរបស់ប្រជាជន ជាពិសេសកុមារ។ ក.ជ.ក. មិនតាមដានត្រួតពិនិត្យសូចនាករធាតុចូលនិងសូចនាករធាតុចេញទេ លើកលែងតែក្នុងករណីមួយចំនួនប៉ុណ្ណោះ។

ផែនការសកម្មភាពភាពជាតិនេះបានកំណត់សូចនាករ លទ្ធផលសំខាន់ៗដូចមានចែងតារាងអនុវត្តការងារ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។ ការសម្រេចបានសូចនាករទាំងនេះ ត្រូវតែស៊ីគ្នាជាមួយចំណុចដៅដែលបានកំណត់នៅពេលវេលានៃការអនុវត្តផែនការជាក់ស្តែង (នៅពេលណាមួយផ្សេងទៀត) ដូចជាអត្រាភាពក្រីក្រកុមារ អត្រាមរណទារក ឬសូចនាករតំណាងឱ្យការការពារកុមារ។ ចំណុចដៅនីមួយៗ ត្រូវបានកំណត់ឱ្យមានសង្គតិភាពជាមួយកម្មវិធីតាមវិស័យ(ធាតុចេញ) និងភ្ជាប់ជាមួយថវិកា(ធាតុចូល)។ ចំណុចដៅដែលបង្កើតឡើង ត្រូវមានសង្គតិភាពជាមួយចំណុចដៅក្នុងផ.យ.អ.ជ.។

ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃ មានលក្ខណៈបត់បែនបានដែលអាចនឹងមានបន្ថែមសូចនាករថ្មី (ឬលុបចោល ឬកែសម្រួលសូចនាករដែលមានស្រាប់) ទៅតាមភាពចាំបាច់។ ជំហាននៃការបង្កើតសូចនាករថ្មី (ឬលុបចោល/កែសម្រួលសូចនាករដែលមានស្រាប់) មានដូចខាងក្រោម៖

១- ក្រសួង ស្ថាប័នពាក់ព័ន្ធ អាចស្នើសុំធ្វើការផ្លាស់ប្តូរដោយផ្អែកលើក្របខ័ណ្ឌលទ្ធផល។

២- សំណើការបង្កើតសូចនាករថ្មី (ឬលុបចោល/ឬកែសម្រួលសូចនាករដែលមានស្រាប់) នឹងត្រូវយកមកពិភាក្សានៅក្នុងក្រុមការងារបច្ចេកទេសដើម្បីកុមារ ដើម្បីវាយតម្លៃសារៈសំខាន់ៗរបស់សូចនាករថ្មីនិងលទ្ធភាពរកទិន្នន័យសម្រាប់ធ្វើការវាស់វែង។

៣- ប្រសិនបើទិន្នន័យថ្មីត្រូវបង្កើតថ្មី នោះលទ្ធភាពនៃការបង្កើតទិន្នន័យដែលមានគុណភាពអាចទទួលយកបានទាំងនេះ នឹងត្រូវធ្វើការវាយតម្លៃប្រកបដោយនិរន្តរភាព ។

៤- ការសម្រេចចិត្តនឹងត្រូវរាយការណ៍ទៅក្រុមការងារជាតិសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃនៃអន្តរក្រសួង ដែលមានទីតាំងនៅក្រសួងផែនការ និងតំណាង ក.ជ.ក. ផងដែរ។

## ៦.២- ភាពត្រួតស៊ីគ្នានៃទិន្នន័យ

មានស្ថាប័នច្រើនដែលប្រមូលទិន្នន័យលើបញ្ហាជាច្រើន ដូចជាលទ្ធផលនៃការអភិវឌ្ឍសុខភាពកុមារ ភាពងាយរងគ្រោះ ពិការភាព ភាពក្រីក្រកុមារ ពលកម្មកុមារជាដើម ដោយប្រើប្រាស់វិធីសាស្ត្រពីរប្រភេទ គឺអង្កេតនិងការកត់ត្រាតាមបែបរដ្ឋបាល។ រហូតមកដល់ពេលនេះ ការសម្របសម្រួលរវាងស្ថាប័ននៅមានកម្រិត ការកំណត់បម្រែបម្រួលនិងដំណើរការផលិតទិន្នន័យ ជាទូទៅ មិនអាចប្រៀបធៀបគ្នាបានរវាងភ្នាក់ងារស្ថាប័នមួយទៅនឹងភ្នាក់ងារស្ថាប័នផ្សេងៗទៀតនោះទេ ព្រោះថាស្ថាប័នមួយចំនួនមិនយកតាមការកំណត់និយមន័យរបស់អន្តរជាតិ ឬការទទួលស្គាល់រួមពីថ្នាក់ជាតិនោះទេ។

នេះគឺជាហេតុផលមួយដែលផែនការនេះស្នើឱ្យបង្កើតគណៈកម្មការជាន់ខ្ពស់មួយ ដើម្បីដោះស្រាយបញ្ហាទិន្នន័យទាក់ទងនឹងកុមារ។ គណៈកម្មការនេះ ត្រូវរាប់បញ្ចូលទាំងទិន្នន័យពីបណ្តាក្រសួង ស្ថាប័នដែលជាអ្នកបង្កើតនិងប្រមូលទិន្នន័យជាមួយនឹងការដឹកនាំដោយ ក.ជ.ក ដែលជាប្រធាន។ គណៈកម្មការនេះ ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមការងារជាតិសម្រាប់តាមដានត្រួតពិនិត្យនិងការវាយតម្លៃថ្នាក់ជាតិ។

## ៦.៣- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃនៅថ្នាក់ជាតិ

រហូតមកដល់ពេលនេះ ការត្រួតពិនិត្យតាមដានរាល់ផែនការទាំងអស់និងកម្មវិធីធំៗ ត្រូវបានធ្វើឡើងនៅថ្នាក់ជាតិ កម្រិតប្រទេស។ ហេតុផលគឺថា កម្ពុជាជាប្រទេសតូចហើយធនធាននៅមានកម្រិត ដូច្នេះវាជាការប្រសើរក្នុងការប្រមូលទិន្នន័យសម្រាប់ប្រទេសដោយបែងចែកជាក្រុមក្នុងការវិភាគ ហើយប្រសើរបំផុតគឺការបែងចែករវាងជនបទនិងប្រជុំជន។ ទិន្នន័យភាគច្រើនត្រូវបានកំណត់ប្រមូលនិងចែកចាយតាមកម្រិតនេះ ។

## ៦.៤- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃនៅថ្នាក់ក្រោមជាតិ

មានសកម្មភាពតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅថ្នាក់ក្រោមជាតិ ប៉ុន្តែរហូតដល់ពេលបច្ចុប្បន្ននេះជម្រើសសម្រាប់ការអនុវត្តកិច្ចការនេះនៅមានកម្រិត ដោយសារធនធាន រចនាសម្ព័ន្ធស្ថាប័ន និងសមត្ថភាពរបស់មន្ត្រីទទួលបន្ទុកនៅមានកម្រិតនៅឡើយ។ ដោយមានការកែលម្អលើការប្រមូលទិន្នន័យនិងការគ្រប់គ្រងក្នុងក្រសួងស្ថាប័នមួយចំនួន ទិន្នន័យរដ្ឋបាលតាមរាជធានី ខេត្តអាចត្រូវបានបង្កើតជាកម្រងទិន្នន័យក្នុងវដ្តផែនការ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យរដ្ឋបាល។ លើសពីនេះទៀត វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានពង្រីកទំហំនៃដំណើរការផលិតទិន្នន័យ ដែលតម្រូវឱ្យមានការបង្កើតកម្រងទិន្នន័យពីអង្កេតនានានៅថ្នាក់ក្រោមជាតិ។ កម្រងទិន្នន័យទាំងនេះមានដូចខាងក្រោម៖

១. ទិន្នន័យស្តីពីសូចនាករសេដ្ឋកិច្ច សង្គមកិច្ចនឹងត្រូវបានរៀបចំឡើងដោយប្រើប្រាស់ទម្រង់ស្ថិតិរាជធានី ខេត្ត ដែលក្រសួង ស្ថាប័នផលិតឡើង ឧទាហរណ៍ អត្រាចុះឈ្មោះចូលរៀននៅក្នុងវិស័យអប់រំឬការគ្របដណ្តប់សុខភាព។

២. ទិន្នន័យឃុំ សង្កាត់ អាចត្រូវបានប្រើប្រាស់សម្រាប់រៀបចំកម្រងទិន្នន័យនៅថ្នាក់រាជធានី ខេត្ត ថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ផងដែរ។ ទោះបីយ៉ាងនេះក្តី ទិន្នន័យទាំងនេះអាចប្រើប្រាស់បាននៅពេលទិន្នន័យឃុំ សង្កាត់ក្លាយជាស្ថិតិផ្លូវការ និងត្រូវពិនិត្យវិនិច្ឆ័យដោយសហគមន៍ អ្នកប្រើប្រាស់ក្នុងរាជរដ្ឋាភិបាលនិងស្ថាប័នស្ថិតិរបស់រាជរដ្ឋាភិបាល។

៣. ទិន្នន័យអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា អាចបំបែកតាមការប៉ាន់ស្មានតាមរាជធានី ខេត្តដូចជាអត្រាមរណភាពទារក អត្រាមរណកុមារអាយុក្រោម៥ឆ្នាំ កង្វះអាហារូបត្ថម្ភកុមារ និងសូចនាករផ្សេងៗទៀត។

នៅកម្រិតទី២នេះ មានគោលបំណងបង្ហាញឱ្យឃើញនូវការប្រមូលទិន្នន័យវឌ្ឍនភាពរបស់កុមារតាមបញ្ជីសូចនាករថ្នាក់រាជធានី ខេត្ត។ នេះការងារលើកទី១នៅកម្ពុជាដែលអាចបង្ហាញពីគោលបំណង ទិន្នន័យ តាមដានត្រួតពិនិត្យនិងវាយតម្លៃនៅថ្នាក់ជាតិ។ លើសពីនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងនេះនឹងវាយតម្លៃលើគុណភាពនៃចរន្តព័ត៌មានដែលមានតម្លៃត្រូវបកស្រាយ។ មានការជឿជាក់ថា ការងារនេះនឹងមានភាពរលូននៅពេលអនុវត្តជាក់ស្តែង។

## ៦.៥- ករណីសិក្សានិងការសិក្សាខ្នាតតូច

ករណីសិក្សានិងការសិក្សាខ្នាតតូច មិនមែនជាការកើតឡើងដោយស្វ័យប្រវត្តនូវជាតុចេញនោះទេ។ ប្រសិនបើមានជាតុចូលគ្រប់ទាំងអស់ឬប្រសិនបើមានជាតុចេញរួចរាល់ហើយ នោះនឹងមានលទ្ធផល/ផលប៉ះពាល់ដោយស្វ័យប្រវត្តដែរ។ ការទាំងនេះអាចបណ្តាលពីហេតុផលជាច្រើនដែលអាចចែកជាបីក្រុមយ៉ាងតិច រួមមានបច្ចេកទេស (ជាតុចូលជាធនធានមិនមានដូចការរំពឹងទុក) នីតិវិធីការងារ(មនុស្សមាននីតិវិធីអនុវត្តផ្សេងៗគ្នា) និងស្ថាប័ន (ប្រព័ន្ធស្ថាប័នមិនគោរពតាមលក្ខខណ្ឌ តម្រូវការនៃក្របខ័ណ្ឌលទ្ធផល)។

ករណីសិក្សានិងការសិក្សាខ្នាតតូចមានប្រយោជន៍ណាស់សម្រាប់ការយល់ដឹងពីបញ្ហាទាំងនេះ។ ការសិក្សាខ្នាតតូចត្រូវកំណត់តំបន់ភូមិសាស្ត្រតូចៗនិងមានគោលបំណងជាក់លាក់ ប៉ុន្តែត្រូវការវិភាគលើបញ្ហានីមួយៗឱ្យបានស៊ីជម្រៅ។ ការសិក្សាខ្នាតតូចអាចឆ្លើយតបនឹងសំណួរនានា ដូចជាហេតុអ្វីបានធ្វើឬមិនបានធ្វើ។ ឧទាហរណ៍ ការសិក្សាខ្នាតតូចមានប្រយោជន៍សម្រាប់ការវិភាគគោលនយោបាយ ដូចខាងក្រោម៖

១- ការសិក្សាតែ១ដង (ការសិក្សាទៅលើចំណេះដឹង អាកប្បកិរិយា និងការអនុវត្ត ការសិក្សាទាក់ទងទៅនឹងសន្តិសុខរបស់កុមារ) គឺដើម្បីបង្កើតព័ត៌មានមូលដ្ឋាននិងចំណេះដឹង។ សនិទានភាពនិងបុព្វហេតុរួមសំខាន់ៗ ដូចជា ហេតុអ្វីបានជាមនុស្សប្រព្រឹត្តឬជឿទៅលើវិធីដែលពួកគេធ្វើ ហេតុអ្វីបានជាការអនុវត្តបន្តហាក់ដូចជាមិនសមហេតុផល តើអ្វីនៅតែកើតមានឧបសគ្គរវាងមនុស្សនិងក្រុមផ្សេងៗ ហេតុអ្វីបានជាមានគំរូក្នុងការប្រើប្រាស់ធនធានដែលមានសមភាពយេនឌ័រក្នុងការទទួលបានធនធាន។ល។ ការទាំងនេះត្រូវមានការស្វែងយល់តាមរយៈការសិក្សា។

២- ការសិក្សាមុននិងក្រោយជួយដល់ការវាយតម្លៃផលប៉ះពាល់របស់គម្រោងឬកម្មវិធីដល់អ្នកទទួលផលប្រយោជន៍ឬប្រជាជនដែលប៉ះពាល់ ជាពិសេសកុមារ។

៣- ការសិក្សាអាចប្រៀបធៀបរវាងអ្នកទទួលផលប្រយោជន៍និងក្រុមអ្នកតាមដានត្រួតពិនិត្យ ដែលអាចជួយដល់ការកំណត់ពីផលប៉ះពាល់នៃគម្រោងចំពោះប្រជាជន។

ការសិក្សានីមួយៗ អាចប្រើប្រាស់វិធីសាស្ត្រផ្ដោតលើបរិមាណ ឬផ្ដោតលើគុណភាព ឬអាចប្រើប្រាស់ទាំងពីរវិធីសាស្ត្រក៏បានតាមភាពចាំបាច់។

នៅកម្រិតទី៣នេះ មានគោលបំណងដើម្បីធ្វើការសិក្សាគំរូយ៉ាងតិចក៏មានការសិក្សា១ក្នុង១ឆ្នាំ ក្នុងភាពជាដៃគូជាមួយក្រសួងដែលកំណត់ជ្រើសរើសប្រធានបទ។

## ៦.៦- គំរូនៃការសរសេររបាយការណ៍និងវាយតម្លៃ

ផែនការនេះត្រូវសរសេររបាយការណ៍ប្រចាំឆ្នាំស្ដីពីស្ថានភាពកុមារ។ របាយការណ៍ទាំងអស់ត្រូវរំលេចអំពីវឌ្ឍនភាពប្រចាំឆ្នាំ តាមរយៈសូចនាករនីមួយៗដូចដែលបង្ហាញនៅក្នុងតារាងអនុវត្តការងារ។

១- នៅថ្នាក់ជាតិ របាយការណ៍ត្រូវប្រមូលផ្ដុំដោយសរសេរតាមទម្រង់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

២-នៅថ្នាក់រាជធានី ខេត្ត ដោយសាររបាយការណ៍នេះជាលើកទី១ សម្រាប់នៅថ្នាក់រាជធានី ខេត្ត ខ្លឹមសារនៃការសរសេររបាយការណ៍ ត្រូវពិនិត្យ និងត្រូវសិក្សាស្រាវជ្រាវ វាយតម្លៃពីគុណភាព ទិន្នន័យ និងមធ្យោបាយនានាដែលសម្រេចអនុម័ត។ ការបង្ហាញរបាយការណ៍ផ្នែកនេះនឹងត្រូវរំលេចពីភាពប្រសើរឡើងក្នុងការអនុវត្តនៅឆ្នាំបន្តបន្ទាប់ ក្នុងរយៈពេលអនុវត្តផែនការនេះ។

៣-ត្រូវសរសេរបង្ហាញពីករណីសិក្សាយ៉ាងតិចឱ្យបានមួយនៃការសិក្សាខ្នាតតូច មធ្យម ដែលចងក្រងឡើងជារៀងរាល់ឆ្នាំក្នុងរយៈពេលអនុវត្តផែនការនេះ។

របាយការណ៍ប្រចាំឆ្នាំនឹងមានបីផ្នែកគឺ៖ ផ្នែកទី១ បង្ហាញពីការអនុវត្តថ្នាក់ជាតិ ផ្នែកទី២ បង្ហាញពីការអនុវត្តនៅថ្នាក់ខេត្ត និងផ្នែកទី៣ បង្ហាញករណីសិក្សាដោយឡែកៗជារៀងរាល់ឆ្នាំ។

ចំពោះការងារដ៏សំខាន់នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.) នឹងពង្រឹងពង្រីកការងារត្រួតពិនិត្យតាមដាន និងវាយតម្លៃនៅក្នុងស្ថាប័ននេះ។ ក.ជ.ក. នឹងទទួលខុសត្រូវប្រមូលនិងចែកចាយទិន្នន័យមកពីប្រភពផ្សេងៗ និងសម្រួលសម្អាតទិន្នន័យ ដើម្បីធ្វើការប្រៀបធៀបទាំងពេលវេលាអនុវត្ត និងទំហំព័ត៌មានប្រចាំឆ្នាំ មុននឹងរៀបចំសរសេររបាយការណ៍។ ក.ជ.ក. នឹងរៀបចំការសិក្សាតាមវិស័យដោយសហការក្នុងភាពជាមួយដៃគូជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដោយជ្រើសរើសប្រធានបទសម្រាប់ករណីសិក្សា។



ក៣

# ៧- សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ ២០១៦-២០១៨ ត្រូវតែអនុវត្តប្រកបដោយជោគជ័យ បន្ទាប់ពីបានការអនុម័តពីរាជរដ្ឋាភិបាល ដោយមានការគាំទ្រថវិកាពីដៃគូអភិវឌ្ឍនានា និងថវិកាជាតិតាមបណ្តាក្រសួង ស្ថាប័នអនុវត្ត ក្រោមការដឹកនាំសម្របសម្រួលពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារ មានតួនាទីដ៏សំខាន់ក្នុងការចូលរួមចំណែកដោះស្រាយបញ្ហាកុមារដែលកំពុងប្រឈមចំពោះមុខ ដើម្បីលើកកម្ពស់សិទ្ធិកុមារឱ្យទទួលបានសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរទៅតាមគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន ពិសេសសិទ្ធិកុមារគឺ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលការការពារ សិទ្ធិអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួមដែលរាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់ និងចាត់វិធានការគ្រប់បែបយ៉ាងនិងគ្រប់វិស័យដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងការអភិវឌ្ឍប្រកបដោយសមភាពនិងសមធម៌របស់កុមារ។ ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍកុមារនេះ នឹងលើកកម្ពស់វិស័យកុមារតាមគោលដៅអាទិភាព ដោយផ្តោតលើការកាត់បន្ថយអត្រាមរណភាពរបស់មាតា ទារក បង្កើនការចុះឈ្មោះចូលរៀនរបស់កុមារ ការបង្ការទប់ស្កាត់និងវិធានការការពារកុមារពីការរំលោភបំពាន ការជួញដូរកុមារ និងអំពើហិង្សាលើកុមារ ការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មទៅក្នុងសង្គមឱ្យមានការងារសមរម្យ និងការចាត់វិធានការតាមផ្លូវច្បាប់។

ទន្ទឹមនឹងនេះ ការអនុវត្តផែនការសកម្មភាពជាតិ គឺត្រូវបំពេញបន្ថែមទៅលើផែនការទៅតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនិងតួនាទីទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងកុមារខ្លួនឯងផ្ទាល់ក្នុងការចូលរួមសម្រេចឱ្យបាននូវជីវភាពរស់នៅរបស់កុមារគ្រប់រូបៗកាន់តែប្រសើរ ដែលជាធនធានសម្រាប់សង្គមនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ព្រោះកុមារគឺជាអ្នកដឹកនាំ និងជាឆ្អឹងខ្នងនៃសង្គមនាពេលអនាគត។ ដូច្នេះ ការវិនិយោគ ការថែទាំ និងការការពារកុមារនៅថ្ងៃនេះ នឹងធ្វើឱ្យពួកគេក្លាយជាមនុស្សមានសុខភាពល្អ មានជំនាញ ជាសសរទ្រូងនៃប្រទេសជាតិយើងនាពេលអនាគត ដែលយើងទាំងអស់ជាក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ឪពុក ម្តាយ អាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងសហគមន៍ផ្ទាល់ មានកាតព្វកិច្ចដ៏សំខាន់ក្នុងការលើកកម្ពស់និងការពារសិទ្ធិរបស់ពួកគេ ដើម្បីប្រែក្លាយពួកគេជាធនធានប្រកបដោយសក្តានុពល ទាំងនៅពេលបច្ចុប្បន្ននិងទៅអនាគត។

# សន្ទានុក្រម

**កុមារ** សំដៅដល់ជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ។

**ការអភិវឌ្ឍកុមារ** សំដៅដល់ភាពរីកចម្រើនក្នុងការបំពេញសិទ្ធិដល់កុមារដែលត្រូវទទួលបាន រួមទាំងការការពារនិងការចូលរួម ដែលធានាថាកុមារគ្រប់រូបត្រូវបានការពារប្រឆាំងរាល់ទម្រង់នៃការរំលោភបំពាន ការគំរាមកំហែង និងការជួញដូរ ការការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌ ឧក្រិដ្ឋកម្ម និងការស្ដារសម្បទាសម្រាប់កុមារដែលទទួលរងគ្រោះដោយអំពើជួញដូរ ឬការរំលោភបំពានផ្សេងៗ រួមទាំងការថែរក្សាពិសេសសម្រាប់កុមារកៀសខ្លួន និងកុមារពិការ។

**កុមារតូច** គឺសំដៅដល់កុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម៦ឆ្នាំ។

**ពលកម្មកុមារ** សំដៅដល់កុមារទាំងឡាយដែលមានអាយុក្រោម១៨ឆ្នាំ ដែលបានចូលរួមក្នុងការងារទទួលប្រាក់កម្រៃ ឬមិនទទួលប្រាក់កម្រៃ ដែលការងារទាំងនោះប៉ះពាល់ដល់ប្រាជ្ញាស្មារតី រាងកាយ ការសិក្សាអប់រំរបស់កុមារ។ ការងារកុមារធ្វើដើម្បីជួយដល់ការអប់រំ ហ្វឹកហាត់បណ្ដុះបណ្ដាលជំនាញសម្រាប់អនាគតរបស់កុមារ នោះមិនមែនជាពលកម្មកុមារឬការងារធ្ងន់ធ្ងររបស់កុមារទេ។

**ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ** សំដៅដល់១- គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬការអនុវត្តប្រហាក់ប្រហែលទៅទាសភាព ដូចជាការលក់ និងការជួញដូរកុមារ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះគេដាច់ថ្លៃ ការងារដោយបង្ខំឬការងារដោយកាតព្វកិច្ច រួមទាំងការជ្រើសរើសដោយបង្ខំ ឬដោយកាតព្វកិច្ចដើម្បីឱ្យបម្រើក្នុងជម្លោះប្រដាប់អាវុធ ២-ការប្រើប្រាស់ ការអូសទាញ ឬការផ្ដល់ឱ្យកុមារបម្រើក្នុងពេស្យាកម្ម ការផលិតរូបភាពអាសគ្រាម ឬការសម្ដែងអាសគ្រាម ៣-ការប្រើប្រាស់ ការអូសទាញ ឬផ្ដល់ឱ្យកុមារបម្រើក្នុងសកម្មភាពខុសច្បាប់ជាពិសេស ការផលិត និងការជួញដូរគ្រឿងញៀនដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានា ៤-ការងារទាំងឡាយណាដែលមានលក្ខណៈ ឬស្ថានភាពរបស់វានៅពេលដែលត្រូវបានគេអនុវត្តអាចនឹងបណ្ដាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ។